**Declassified to Public**
**12 April 2013**

D378/2

**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០១០

**ឯកសារដើម**
**DOCUMENT RECEIVED/DOCUMENT REÇU**
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 23 / 06 / 2010
ម៉ោង (Time/Heure): 16:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ

ប្រភេទចំណាត់ថ្នាក់ឯកសារ

ការពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 28 / 06 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

---

**ញត្តិផ្សេងទៀតរបស់លោក អៀង សារី ស្តីពីព្រំដែនកម្រិត**
**លទ្ធភាពអនុវត្ត ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅ អវតក**

---

| <u>ដាក់ដោយ</u>៖ | <u>ផ្ញើជូន</u>៖ | <u>ផ្ញើជូន</u>៖ |
|---|---|---|
| **សហមេធាវី:** | **សហចៅក្រមស៊ើបអង្កេត** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្តម | ចៅក្រម យូ ប៊ុនឡេង | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម Marcel LEMONDE | លោក Andrew CAYLEY |
| | | |
| | | ក្រុមមេធាវីការពារក្តីទាំងអស់ |

[signature]

អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ លោក អៀង សារី តាមរយៈសហមេធាវីការពារក្ដីរបស់គាត់ ("សហមេធាវីការពារក្ដី") បានដាក់ការជំទាស់តវ៉ាទៅលើ យុត្តាធិការស្ដីពីកម្រិតព្រំដែននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រសិនណា កសចស យល់ឃើញថា ខ្លួនមានយុត្តាធិការទៅលើឧក្រិដ្ឋកម្មទាំងនេះ[1]។ ការជំទាស់តវ៉ាលើយុត្តាធិការនេះ ត្រូវបានធ្វើឡើងជាចាំបាច់ដោយ ហេតុថានិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចមានចែងនៅក្នុងច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀង បានឃ្លាតឆ្ងាយពីច្បាប់ទំនៀមអន្តរជាតិក្នុងចន្លោះឆ្នាំ ១៩៧៥-១៩៧៩ នៅក្នុងទិដ្ឋភាពជាច្រើនចំណុច[2]។ អវតក មានកាតព្វកិច្ចអនុវត្តច្បាប់ដែលនៅជាធរមាននៅក្នុងចន្លោះពេលនោះ។

## I. ច្បាប់ជាធរមាន

### ក. ការដកស្រង់ចេញពីច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា កិច្ចព្រមព្រៀង និង ច្បាប់ស្ដីពី ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ

១. មាត្រា ៥ នៃច្បាប់ស្ដីពីការបង្កើត អវតក ចែងក្នុងផ្នែកពាក់ព័ន្ធថា៖

---

[១] *សូមមើលរឿងក្ដី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស សំណើសុំរបស់ លោក អៀង សារី ប្រឆាំងនឹងការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អ.វ.ត.ក ឯកសារ D378 ERN: 00498540-00498552 (ពាក្យសុំលើកទីមួយអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)។

[២] ទាក់ទងនឹងសាលដីកាថ្មីៗនេះរបស់អង្គបុរេជំនុំជម្រះ ស្ដីពីការអនុវត្តសហឧក្រិដ្ឋកម្មរួមនៅ អវតក ដែលក្នុងនោះ អង្គបុរេជំនុំជម្រះ បានថ្លែងថា អវតក អាចអនុវត្តនូវទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលត្រូវបានគេទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទំលាប់អន្តរជាតិនៅក្នុងរយៈពេលដែលពាក់ព័ន្ធ សហមេធាវីការពារក្ដីសូមធ្វើការកត់សម្គាល់ដើម្បីអោយមានជាកំណត់ហេតុថាខ្លួនមិនលះបង់ចោលនូវអំណះអំណាងនានាតទៅមុខទៀតរបស់ខ្លួនទាក់ទងទៅនឹងឋានៈភាពរបស់ អវតក ជាតុលាការជាតិ ហើយនឹងភាពមិនអាចអនុវត្តបាននៃច្បាប់ទំនៀមទំលាប់អន្តរជាតិរបស់ អវតក ។ *សូមមើលរឿងក្ដី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អបជ ៦០) បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើនៅ អ.វ.ត.ក ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១០ ឯកសារ D345/5/1 ERN: 00491231-00491261 កថាខណ្ឌទី២៩។ *រឿងក្ដី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អបជ ៣៥) បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាស្ដីពីការអនុវត្តទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១០ ឯកសារ D97/14/5 ERN: 00429213-00429253 កថាខណ្ឌទី៧ ដល់ទី៣១។

អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយ ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងអំឡុងពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ៦ ខែមករា ឆ្នាំ១៩៧៩។

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលគ្មានអាជ្ញាយុកាល គឺអំពើទាំងឡាយណាប្រព្រឹត្តឡើង ជាផ្នែកនៃការវាយប្រហារជាទូទៅ ឬ ជាប្រព័ន្ធសំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល ដោយមូលហេតុជាតិនយោបាយ ជាតិពិន្ទុ ពូជសាសន៍ ឬ សាសនាណាមួយ ដូចជា៖.....

២. មាត្រា ៩ នៃកិច្ចព្រមព្រៀងចែងក្នុងផ្នែកពាក់ព័ន្ធថា៖ “យុត្តាធិការលើរឿងក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញ គឺ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចបានកំណត់ក្នុងលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិឆ្នាំ ១៩៩៨...”[3]។

៣. ផ្នែកខ្លះនៃមាត្រា ៣៨ នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ចែងថា “វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ”។

៤. មាត្រា ៣១ នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ចែងក្នុងផ្នែកពាក់ព័ន្ធថា៖

> ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និង គោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស [និង] កតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស...”។

## ក. ចំណានុក្រម និង អន្តរកម្មនៃលិខិតុបករណ៍ច្បាប់ដែលពាក់ព័ន្ធ

---

[3] *ក៏ប៉ុន្តែសូមមើលផងដែរ* ច្បាប់លក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ មាត្រា ១០៖ “ពុំមានចំណុចណាមួយនៃផ្នែកនេះ [យុត្តាធិការ, ភាពអាចទទួលយកបាន និងច្បាប់ជាធរមាន] ត្រូវធ្វើការបកស្រាយថាជាការដាក់កំរិត ឬជាការធ្វើឲ្យខូចខាតទោះក្នុងលក្ខណៈបែបណាក៏ដោយ ដល់វិធាននៃច្បាប់អន្តរជាតិទាំងឡាយដែលមានស្រាប់ ឬដែលកំពុងមានការអភិវឌ្ឍន៍ ដែលមានគោលបំណងផ្សេងពីច្បាប់លក្ខន្តិកៈនេះ”។

៥. អវតក គឺជាតុលាការជាតិកម្ពុជា[4]។ អញ្ចឹងហើយ ទើបនៅក្នុងករណីមានវិវាទកើតឡើង ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាត្រូវប្រើជាអាទិភាពលុបលើកិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អវតក (រួមគ្នាហៅថា "លិខិតុបករណ៍សំខាន់")។ កិច្ចការពារទាំងឡាយដែលមានចែងនៅក្នុង លិខិតុបករណ៍នានាស្តីពីសិទ្ធិមនុស្សអន្តរជាតិ ដែលត្រូវបានរួមបញ្ចូលទៅក្នុងមាត្រា ៣១ នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ត្រូវប្រើជាអាទិភាពចំពោះចំណុចណាមួយដែលមានខ្លឹមសារផ្ទុយនៅក្នុងលិខិតុបករណ៍សំខាន់[5]។ កិច្ចការពារទាំងអស់នេះមានរួមបញ្ចូលគោលការណ៍ *គ្មានបទល្មើសទេ បើគ្មានច្បាប់ចែង* (*nullum crimen sine lege*)[6] គោលការណ៍ *ច្បាប់ណាមានការអនុគ្រោះជាង* (*lex mitior*)[7] និង គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* (*in dubio pro reo*)[8]។ ដូច្នេះ អវតក ត្រូវតែអនុវត្ត ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចដែលបានកំណត់នៅ

---

[4] *សូមមើល ឧទាហរណ៍ រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច"* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក-អ.ប.ជ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧ ឯកសារ C5/45 ERN: 00154285-00154302 កថាខណ្ឌទី១៩។

[5] សូមកត់សម្គាល់ផងដែរថា ការការពារទាំងឡាយដែលមានចែងនៅក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដែលត្រូវបានអនុម័ត និងបើកចំហរសម្រាប់ធ្វើការចុះហត្ថលេខា ការផ្តល់សច្ចាប័ន និងការចូលរួមជាមួយ ដោយសេចក្តីសម្រេចមហាសន្និបាត ២២០០A (XXI) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ចូលជាធរមាន នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦ ("ICCPR") ពាក់ព័ន្ធជាមួយនឹងការអនុវត្តយុត្តាធិការរបស់ អ.វ.ត.ក ក៏ត្រូវបានរួមបញ្ចូលផ្ទាល់ទៅក្នុងលិខិតុបករណ៍សំខាន់នានាផងដែរ។ *សូមមើល* ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៣ថ្មី និងកិច្ចព្រមព្រៀង មាត្រា ១២(២)។

[6] *សូមមើល* សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស G.A. Res. 217A(III), U.N. GAOR, 3d Sess. នៅចំណុច ៧១ ឯកសារអង្គការសហប្រជាជាតិ A/810 (ឆ្នាំ១៩៤៨) មាត្រា ១១(១)។ កតិកាសញ្ញា ICCPR មាត្រា ១៥(១) ដែលបានចែងមួយផ្នែកថា: "ពុំមានជនណាម្នាក់ត្រូវបានលើកឡើងថាមានទោសអំពីបទល្មើសឧក្រិដ្ឋណាមួយឡើយ ចំពោះរឿងរ៉ាវនៃអំពើណាមួយ ឬការខកខានណាមួយដែលគ្មានបទល្មើសឧក្រិដ្ឋ ក្រោមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ នៅពេលដែលវាត្រូវបានប្រព្រឹត្តឡើងនោះឡើយ"។

[7] សូមមើល ICCPR មាត្រា ១៥។ ដោយប្រកាន់ភ្ជាប់ទៅនឹងគោលការណ៍ *ច្បាប់ណាមានការអនុគ្រោះជាង* (*lex mitior*) តម្រូវថា នៅពេលដែលច្បាប់ចងកាតព្វកិច្ចតុលាការត្រូវបានផ្លាស់ប្តូរនាពេលក្រោយមកជាច្បាប់ដែលមានលក្ខណៈអនុគ្រោះជាង ហើយក៏ចងកាតព្វកិច្ចតុលាការនោះផងដែរនោះ ច្បាប់ដែលមានអនុគ្រោះជាងនោះនឹងត្រូវយកមកអនុវត្ត។ *សូមមើល រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Deronjic* សំណុំរឿងលេខ IT-02-61-A សាលដីកា ចុះថ្ងៃទី ៣០ កក្កដា ២០០៥ កថាខណ្ឌ ៩៧។

[8] សូមមើល រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣៨ ។ សូមមើលផងដែរ កថាខណ្ឌ ៣ ខាងលើ ។ នៅតុលាការ ICTY គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ (*in dubio pro reo* ) ត្រូវបានគេទទួលស្គាល់ស្របគ្នាជាមួយនឹងសន្មត់ទុកជាមុនថាគ្មានទោស ហើយនឹងការទទួលបន្ទុកបង្ហាញភស្តុតាងអោយអស់វិមតិសង្ស័យ (រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Delalic et

ក្នុងច្បាប់ទំនៀមអន្តរជាតិ ក្នុងឆ្នាំ ១៩៧៥ ដល់ ១៩៧៩ វៀរលែងតែ និយមន័យនៃឧក្រិដ្ឋកម្មនោះប្រែក្លាយជាមានផលអនុគ្រោះច្រើនជាងចំពោះជនជាប់ចោទ/ត្រូវចោទ ឬក៏ មានករណីសង្ស័យ។ ដូចដែលសហមេធាវីការពារក្តីបានពន្យល់កាលពីលើកមុន[9] ដែលមិនទាន់បានទទួលការសម្រេចពី កសចស នៅឡើយ[10] នៅក្នុងករណីមានវិវាទរវាងលិខិតុបករណ៍សំខាន់ នោះច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញត្រូវមានឧត្តមានុភាព។

៦. កសចស បានធ្វើ "កំណត់សម្គាល់សមគួរ" ចំពោះការចរិតលក្ខណៈនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុង មាត្រា ៧ នៃច្បាប់លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ[11]។ ចំណុចនេះស្រប នឹងមាត្រា ៩ នៃកិច្ចព្រមព្រៀង ដែលមានបំណងផ្តល់យុត្តាធិការលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចមានចែង នៅក្នុងច្បាប់លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិផងដែរ[12]។ ទោះជា កសចស មិនបានផ្តល់សំអាងហេតុនៅដំណាក់កាលនេះក្តី ក៏ "កំណត់សម្គាល់សមគួរ" សន្មតថាត្រូវបានធ្វើឡើង ពីព្រោះមាត្រា ៩ នៃកិច្ចព្រមព្រៀងត្រូវស្របជាមួយនឹង ឬ ត្រូវផ្អែកតាម ទីមួយ ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា រួមទាំង លិខិតុបករណ៍សិទ្ធិមនុស្សនានាដែលត្រូវបានរួមបញ្ចូលក្នុងនោះ និង ទីពីរ ផ្អែកលើច្បាប់ស្តីពីការបង្កើត អវតក[13]។

---

al.,សំណុំរឿង IT-96-21-T សាលក្រម ចុះថ្ងៃទី ១៦ វិច្ឆកា ១៩៩៨ កថាខណ្ឌ៦០១) ។ នៅទីនោះគេបានទទួលស្គាល់ទាក់ទងទៅនឹងការយល់ឃើញទាំងឡាយដែលតំរូវសម្រាប់ការផ្តន្ទាទោស ដូចជាការយល់ឃើញនានាដែលរួមផ្សំបង្កើតបានជាធាតុផ្សំនៃបទល្មើសដែលគេចោទប្រកាន់។ (រឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Limaj et al., សំណុំរឿង IT 33-66-A* សាលក្រម ចុះថ្ងៃទី ២៧ កញ្ញា ២០០៧ កថាខណ្ឌ ២១) ។

[9] *សូមមើលរឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស ចម្លើយតបរបស់ លោក អៀង សារី ទៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងបទឧក្រិដ្ឋនៃការបាត់ខ្លួនដោយបង្ខំ និងសំណើសុំបន្ថែមចំនួនទំព័រដែលបានកំណត់ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩ ឯកសារ D180/4 ERN: 00373977-00373994 ("ចម្លើយតបស្តីពីការបាត់ខ្លួនដោយបង្ខំ") កថាខណ្ឌទី១៦ ដល់ទី២០។

[10] *សូមមើលរឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងការបាត់ខ្លួនដោយបង្ខំ ("ដីកាសម្រេចស្តីពីការបាត់ខ្លួនដោយបង្ខំ") ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D180/6 ERN: 00417295-00417299។

[11] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៨។

[12] *សូមមើល* កថាខណ្ឌ ២ *ដូចខាងលើ*។

[13] *សូមមើល* ចម្លើយតបស្តីពីការបាត់ខ្លួនដោយបង្ខំ កថាខណ្ឌទី១៦ ដល់ទី២០។

## III. ឧទ្ធិករណ៍

### ក. ជនត្រូវចោទ/ជនជាប់ចោទត្រូវតែបានដឹងអំពីការវាយប្រហារ

៧. នៅក្នុងសំណុំរឿង ០០១ កសចស បានយល់ឃើញថា "ការដឹងអំពីការវាយប្រហារ" គឺជាធាតុផ្សំមួយក្នុងចំណោមធាតុផ្សំទាំងឡាយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[14]។ ទោះបីជាគ្មានការបង្ហាញសំអាងហេតុក៏ដោយ តាមការសន្មត កសចស បានដកស្រង់ធាតុផ្សំនេះចេញពីច្បាប់លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (អនុលោមតាមមាត្រា ៩ នៃកិច្ចព្រមព្រៀង)[15]។ និយមន័យក្នុងច្បាប់ស្តីពីការបង្កើត អវតក (ដែលត្រង់ប្រការនេះ មិនប្រើប្រាស់ភាសាឲ្យដូចនឹងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ) ទំនងជាត្រូវបានពឹងផ្អែកលើលក្ខន្តិកៈរបស់ ICTR[16]។ យ៉ាងណាក្តីយុត្តិសាស្ត្ររបស់តុលាការ *ចំពោះកិច្ច* បង្ហាញយ៉ាងច្បាស់លាស់ថា "ការដឹងអំពីការវាយប្រហារ" គឺជាធាតុផ្សំអត្តនោម័តមួយដ៏ចាំបាច់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[17]។ ចំពោះធាតុផ្សំនេះ កសចស

---

[14] *សូមមើល ឧទាហរណ៍ រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច"* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស ដីកាបញ្ជូនជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ទៅជំនុំជម្រះ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ កថាខណ្ឌទី១៣៣៖ "ហេតុនេះ អំពើនានាដែលជាបទល្មើសព្រហ្មទណ្ឌជាមូលដ្ឋានដូចមានរៀបរាប់នៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ដែលត្រូវបានកំណត់លក្ខណៈខាងក្រោមពាក់ព័ន្ធជាមួយនឹងមន្ទីរ ស២១ ត្រូវបានប្រព្រឹត្តឡើងជាផ្នែកមួយនៃការវាយប្រហារ ដែលមានលក្ខណៈទូលំទូលាយ ឬមានលក្ខណៈជាប្រព័ន្ធ នៅមន្ទីរ ស២១ ដែលមានគោលដៅប្រឆាំងនឹងប្រជាជនស៊ីវិល ដោយសារហេតុ ផលនយោបាយ និង<u>ដោយមានការដឹងអំពីការវាយប្រហារនោះ</u> ក្រោមនិយមន័យទំនៀមទម្លាប់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅឆ្នាំ១៩៧៥" (ការគូសបញ្ជាក់ដែលបានបន្ថែម)។

[15] ច្បាប់លក្ខន្តិកៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិ មាត្រា៧។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Germain Katanga និង Mathieu Ngudjolo Chui*, ICC-01/04-01/07 សេចក្តីសម្រេចលើការអះអាងអំពីបទចោទប្រកាន់ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៨ កថាខណ្ឌទី៤០១ (សេចក្តីសម្រេចទទួលយកបទចោទប្រកាន់ក្នុងរឿងក្តី *Katanga)* ។ *សូមមើល* កថាខណ្ឌ ៥ និង ៦ ដូចខាងលើ។

[16] *សូមមើល* ច្បាប់លក្ខន្តិកៈតុលាការ ICTR មាត្រា ៣។

[17] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Gacumbitsi* តុលាការ ICTR-2001-64-A សាលក្រម ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌទី៨៦៖ "ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ "ជនជាប់ចោទត្រូវបានធ្វើសកម្មភាពទាំងឡាយដោយបានដឹងអំពីបរិបទដ៏ទូលំទូលាយនៃការវាយប្រហារ និងបានដឹងថា អំពើរបស់ខ្លួនបានបង្កើតជាផ្នែកមួយនៃការវាយប្រហារដែលមានលក្ខណៈទូលំទូលាយ និងមានលក្ខណៈជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិល"។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kordic & Cerkez*, IT-95-14/2-A សាលដីកា ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ ( "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ *Kordic & Cerkez")* កថាខណ្ឌ

ត្រូវធ្វើតាមការបកស្រាយរបស់ខ្លួននៅក្នុងសំណុំរឿងលេខ ០០១ ដោយបញ្ចូលលក្ខខណ្ឌកំណត់នេះទៅក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អវតក។

## ខ. អំពើជាមូលដ្ឋានតម្រូវឲ្យមានចំណងទាក់ទងគ្នាជាមួយនឹងជម្លោះប្រដាប់អាវុធអន្តរជាតិ

៨. មាត្រា ៣១ នៃច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា តម្រូវឲ្យមានការអនុវត្តគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់* (*nullum crimen sine lege*)[18]។ ដូច្នេះ ចំណងទាក់ទងអំពើជាមូលដ្ឋាន និង ជម្លោះប្រដាប់អាវុធអន្តរជាតិ គឺជាលក្ខខណ្ឌកំណត់នៃ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅ អវតក។ ការអនុវត្តរបស់រដ្ឋ និង*ទស្សនៈច្បាប់* (*opinio juris*) បង្ហាញថា ចំណងទាក់ទងគ្នារវាងអំពើជាមូលដ្ឋាននិងជម្លោះប្រដាប់អាវុធអន្តរជាតិ គឺជា លក្ខខណ្ឌកំណត់នៃឧក្រិដ្ឋកម្មប្រឆាំង

---

៩៩។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blaskic,* IT-95-14-A សាលដីកា ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ ( "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ *Blaskic")* កថាខណ្ឌ ១២៤។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kunarac et al.,* IT-96-23&23/1-A សាលដីកា ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ ៩៩។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadic,* IT-94-1-A សាលដីកា ( "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ *Tadic")* ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ (សាលដីការឿងក្តី *Tadic*) កថាខណ្ឌ ២៧១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blagojevic & Jokic,* IT-02-60-T សាលក្រម ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ( "សាលក្រមជំនុំជម្រះក្នុងរឿងក្តី *Blagojevic & Jokic")* កថាខណ្ឌ ៥៤៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Brdanin,* IT-99-36-T សាលក្រម ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៤ ( "សាលក្រមជំនុំជម្រះក្នុងរឿងក្តី *Brdanin")* កថាខណ្ឌ ១៣៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kupreskic et al.,* IT-95-16-T សាលក្រម ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ ( "សាលក្រមជំនុំជម្រះក្នុងរឿងក្តី *Kupreskic")* កថាខណ្ឌ ៥៥៦។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Limaj et al.,,* IT-03-66-T សាលក្រម ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៥ ( "សាលក្រមជំនុំជម្រះក្នុងរឿងក្តី*Limaj")* កថាខណ្ឌ ១៨៨។ នៅតុលាការពិសេស សម្រាប់ប្រទេសសេរ៉ាឡេអូន វាបង្ហាញឲ្យឃើញថា បទដ្ឋានដែលត្រូវបានប្រើប្រាស់ "ត្រូវបានដឹង ឬមានហេតុផលដើម្បីដឹង"។ *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Fofana & Kondewa* SCSL-04-14-T សាលក្រម ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០០៧ កថាខណ្ឌ ១២១។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sesay et al.,* SCSL-04-15-T សាលក្រម ("សាលក្រមជំនុំជម្រះក្នុងរឿងក្តី*RUF")* ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ៩០ ។

[18] *សូមមើល* កថាខណ្ឌទី ៥ និង ៦ ខាងលើ។

មនុស្សជាតិនៅក្នុងច្បាប់ទំនៀមអន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩[19]។ មូលដ្ឋានច្បាប់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមាននៅក្នុងច្បាប់ស្តីពីសង្គ្រាម[20]។ មាត្រា ៦(គ) នៃធម្មនុញ្ញតុលាការអន្តរជាតិនៅ Nuremberg (“ធម្មនុញ្ញ IMT”) (ដូចដែលត្រូវបានធ្វើវិសោធនកម្មដោយពិធីសារចុះថ្ងៃទី ៦ ខែតុលា)[21] បានចែងថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនអាចមានអត្ថិភាពបានឡើយ លើកលែងតែវាកើតឡើងជាមួយនឹងឧក្រិដ្ឋកម្មសង្គ្រាម ឬ ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព[22]។ សាលក្រមរបស់តុលាការយោធាអន្តរជាតិនៅ Nuremberg (“សាលក្រម IMT”) និង គោលការណ៍

---

[19] បច្ចុប្បន្ននេះ ច្បាប់ទំនៀមទម្លាប់អន្តរជាតិពុំតំរូវអោយ អំពើទាំងឡាយដែលមានចែងក្នុងច្បាប់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវមានការទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធឡើយ។ *សូមមើលរឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadic,* IT-94-1/AR72 សេចក្តីសម្រេចលើសំណើសុំរបស់មេធាវីការពារក្តីសម្រាប់បណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំស្តីពីយុត្តាធិការ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ ១៩៩៥ (“សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីយុត្តាធិការក្នុងរឿងក្តី Tadic”) កថាខណ្ឌ ១៤១។ *សូមមើលរឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blaskic,* IT-95-14 សាលក្រម ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ (“សាលក្រមជំនុំជម្រះក្នុងរឿងក្តី *Blaskic*”) កថាខណ្ឌ៧១។

[20] *សូមមើល* ឧទាហរណ៍ M. CHERIF BASSIOUNI, ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ៧៧ (Kluwer 1999) (“BASSIOUNI”)៖ “សេចក្តីសន្និដ្ឋានមានលក្ខណៈច្បាស់ណាស់ថា “ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ” មានលក្ខណៈស្រដៀងគ្នានឹងឧក្រិដ្ឋកម្មសង្គ្រាម ហើយជាការពង្រីកបន្ថែមលើឧក្រិដ្ឋកម្មសង្រ្គាម និងថា ឧក្រិដ្ឋកម្មទាំងនេះត្រូវបានផ្អែកលើ គោលការណ៍ស្មារតី និងគោលការណ៍ច្បាប់ដូចគ្នាដែលមានជាយូរមកហើយ និងដែលជាការគាំទ្រដល់គោលការណ៍នានា បទដ្ឋាននានា និងវិធាននានានៃការធ្វើឲ្យមានមនុស្សធម៌ និង បញ្ញត្តិអំពីជម្លោះប្រដាប់អាវុធ”។ *សូមមើល ផងដែរ Egon Schwelb ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* ២៣ BYBIL 178, 206 (ឆ្នាំ១៩៤៦) *(Schwelb)* ៖ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចដែលបានបកស្រាយនៅក្នុងសាលក្រមរបស់តុលាការយោធាអន្តរជាតិ គឺជាឧក្រិដ្ឋកម្ម “ដែលប្រព្រឹត្តតាម” ឬ “ដែលបន្ទាប់បន្សំ” នៃឧក្រិដ្ឋកម្មនានា ប្រឆាំងសន្តិភាព ឬការរំលោភលើច្បាប់ និងទំនៀមទម្លាប់នៃសង្គ្រាម”។

[21] កិច្ចដំណើរការនីតិវិធីជំនុំជម្រះ Nuremberg Volume I: ពិធីសារដែលកែតម្រូវភាពមិនស្របគ្នានៅក្នុងធម្មនុញ្ញ (ថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៤៥) (“ពិធីសារចុះថ្ងៃទី៦ ខែតុលា”) ដែលអាចបើកមើលបាននៅ http://avalon.law.yale.edu/imt/imtprot.asp ។

[22] *សូមមើល* Leslie C. Green *បទបញ្ញត្តិច្បាប់អន្តរជាតិស្តីពីជម្លោះប្រដាប់អាវុធ* នៅក្នុងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ទំព័រ ១ ៣៥៥, ៣៦៩ (M. Cherif Bassiouni ed., បោះពុម្ពផ្សាយលើកទី២ ឆ្នាំ១៩៩៩) *ដែលបានដកស្រង់នៅក្នុង Stuart Ford ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា: តើការទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធមានលក្ខណៈចាំបាច់ដែរឬទេ?* 24 UCLA Pac. Basin L.J. 125, n. 70 (ឆ្នាំ២០០៦ ដល់ឆ្នាំ២០០៧)។

Nuremberg[23] ឆ្លុះបញ្ចាំងអំពីការយល់ឃើញនេះ[24]។

៩. កិច្ចពិភាក្សានានានៅឯគណៈកម្មការច្បាប់អន្តរជាតិ (“ILC”) នៅចុងទសវត្សរ៍ឆ្នាំ ១៩៤០ និង ដើមទសវត្សរ៍ឆ្នាំ ១៩៥០ ពាក់ព័ន្ធនឹង *ការអភិវឌ្ឍច្បាប់អន្តរជាតិដែលកើនឡើងជាលំដាប់*[25] បង្ហាញថា

---

[23] គោលការណ៍នានានៃច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់នៅក្នុងធម្មនុញ្ញនៃតុលាការ *Nuremberg និងនៅក្នុងសាល់ក្រមរបស់តុលាការនេះ U.N Doc. A/1316 (1950) (គោលការណ៍ Nuremberg)* គោលការណ៍ VI(c) ។ សូមមើលផងដែរ ការបញ្ជាក់អះអាងអំពីគោលការណ៍នៃច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់ដោយតុលាការ Nuremberg ដែលត្រូវបានអនុម័តនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៤៦ G.A. Res. 95(1), U.N. G.A.O.R កិច្ចប្រជុំលើកទី ១ សម័យប្រជុំលើកទី៥៥ Mtg., ឯកសារអង្គការសហប្រជាជាតិ A/64/Add.1 (ឆ្នាំ១៩៤៦) នៅ ចំណុច ១៨៨ ។

[24] សាលក្រមរបស់តុលាការយោធាអន្តរជាតិ សម្រាប់ការជំនុំជម្រះក្តីឧក្រិដ្ឋជនសង្គ្រាមដ៏សំខាន់ៗរបស់អាល្លឺម៉ង់ Nuremberg ចុះថ្ងៃទី៣០ ខែកញ្ញា និងចុះថ្ងៃទី១ ខែ តុលា ឆ្នាំ១៩៤៦ ទីក្រុងឡុង H.S.S.O សេចក្តីផ្សេងៗ លេខ១២ (ឆ្នាំ១៩៤៦) នៅចំណុច ២៥៤។ ទោះបីជា លក្ខខណ្ឌកំណត់នៃជម្លោះប្រដាប់អាវុធត្រូវបានដកចេញពីមាត្រា II នៃច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ ក៏ដោយ (១) ការទាក់ទងផ្នែកយុត្តាធិការទៅនឹងធម្មនុញ្ញតុលាការយោធាអន្តរជាតិ នៅក្នុងច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ មាត្រា I បានផ្តល់នូវការពិភាក្សាអំពី លទ្ធផលនៃការលុបចោលនេះ ដោយមានការតម្រូវជាញឹកញាប់ដោយចៅក្រមថាត្រូវមានចំណងទាក់ទងរវាងសង្គ្រាម និងអំពើនានារបស់ជនជាប់ចោទ និង (២) តុលាការរបស់ប្រទេសជាសម្ព័ន្ធមិត្រ និងតុលាការអាល្លឺម៉ង់ដែលអនុវត្តនូវច្បាប់នេះ គឺជា “តុលាការជាតិដែលជាធម្មតាប្រើប្រាស់ច្បាប់ជាតិ (ច្បាប់ក្នុងស្រុក) ដែលការពិតនោះបានបញ្ចូលនូវបទបញ្ញត្តិនានាដែលមាន ដើមកំណើតចេញមកពីអាជ្ញាធរដែលត្រួតត្រាប្រទេសនោះ”។ Schwelb, ត្រង់ចំណុច ២១៨ ដល់ ២១៩។

[25] *សូមមើល* សេចក្តីព្រាងក្រមស្តីពីបទល្មើសនានាប្រឆាំងសន្តិភាព និងសន្តិសុខរបស់ប្រជាជាតិ របាយការណ៍ធ្វើដោយ J. Spiropsoulos អ្នករាយការណ៍ពិសេស ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៥០ (“សេចក្តីព្រាងក្រមស្តីពីបទល្មើសនានា”) ដែលអាចបើកមើលបាននៅក្នុង 2 Y.B. INT'COMM'N ត្រង់ចំណុច២៥៣, ២៥៥ កថាខណ្ឌ ២ (ឆ្នាំ ១៩៥០) (ដែលបានកត់សម្គាល់ថាអ្នករាយការណ៍ពិសេសមិនមែនជាអ្នកសរសេរអោយទៅជាច្បាប់នូវច្បាប់អន្តរជាតិដែលមានស្រាប់ ប៉ុន្តែគ្រាន់តែជាអ្នកដែលធ្វើការងារពាក់ព័ន្ធជាមួយនឹងការងារដែលមាន “លក្ខណៈប៉ាន់ស្មាន” ច្រើនជាង)។ *សូមមើលផងដែរ* ដូចជើងទំព័រខាងលើ ២៥៧ កថាខណ្ឌទី២០ (ដោយកត់សម្គាល់ឃើញថា ILC បានពិភាក្សាគ្នាអំពីបញ្ហានេះ និងបានសន្និដ្ឋានថា សេចក្តីព្រាងក្រមស្តីពីបទល្មើសនានាបានតំណាងឲ្យ “ការអភិវឌ្ឍដ៏ជឿនលឿននៃច្បាប់អន្តរជាតិ”)។ សាលដីកាJCE ត្រង់កថាខណ្ឌទី៦១។ គេបានលើកឡើងថា នៅពេលដែលគ្មានលក្ខខណ្ឌកំណត់នៃចំណងទាក់ទងនៅក្នុងអនុសញ្ញាស្តីពីការការពារ និងការដាក់ទោសលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (“អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍”) (G.A. Res. 260(III) (ថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨)) វាមិនសំខាន់នោះទេ។ *សូមមើល* Guenael Mettraux *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងសម្រាប់រ៉ាន់ដា* 43 Harv. Int"l L.J. 237, 302-306, (ឆ្នាំ២០០២)។ សេចក្តីព្រាងក្រមស្តីពីបទល្មើសនានា បានសង្កេតឃើញថា ការមិនមានលក្ខខណ្ឌកំណត់អំពីចំណងទាក់ទងនៅក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជ

ចំណងទាក់ទងរវាងអំពើជាមូលដ្ឋាននិងជម្លោះប្រដាប់អាវុធអន្តរជាតិ ត្រូវបានយល់ឃើញថាជាតម្រូវការផ្នែកច្បាប់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅអំឡុងរយៈពេលនោះ[26]។ ចាប់ពីទសវត្សរ៍ឆ្នាំ ១៩៥០ ដល់ឆ្នាំ ១៩៧៩ មានភស្តុតាងបន្តិចបន្តួចប៉ុណ្ណោះអំពីការអនុវត្តទូទៅក្នុងចំណោមរដ្ឋនានា និង *ទស្សនៈច្បាប់* (*opinio juris*) ដែលថា ចំណងទាក់ទងគ្នានេះមិនមែនជាធាតុផ្សំដ៏ចាំបាច់ទៀតឡើយ[27] ហើយការជំទាស់ទៅនឹងការដកចេញនេះបានបន្តធ្វើរហូតដល់មានការចរចានានា

---

សាសន៍ វាត្រូវបានយល់ឃើញថាជាកត្តាបែងចែកពីគ្នានៃឧក្រិដ្ឋកម្មនោះ ពោលគឺ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ *សូមមើល* សេចក្តីព្រាងក្រមស្តីពីបទល្មើសនានា ត្រង់ចំណុច ២៦៣ កថាខណ្ឌទី៦៥។ សូមមើលផងដែរ Ford ត្រង់ចំណុច ១៥២-១៥៣។

[26] សូមមើលសេចក្តីសង្ខេបនៃកិច្ចប្រជុំលើកទី៤៨ របស់ ILC នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៥០ ត្រង់ទំព័រ ៣៦៤ និង ៣៧៧ ដែលមាននៅលើគេហទំព័រ http://untreaty.un.org/ilc/documentation/english/a_cn4_34.pdf។

[27] សូមមើល Ford, ពីទំព័រ១៥៩ ដល់១៦៧ ដោយកត់សំគាល់ថាអនុសញ្ញាឆ្នាំ១៩៦៨ស្តីពីការមិនអាចអនុវត្តបាននៃច្បាប់អាជ្ញាយុកាលឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺ (ក)សំខាន់បំផុតវាគឺជាឯកសារនយោបាយដែលបានប្រមូលការគាំទ្រនូវចំនួនតិចជាងពាក់កណ្តាលពីចំនួនរដ្ឋដែលជាសមាជិករបស់អង្គការសហប្រជាជាតិ(ពីទំព័រ១៦១ ដល់១៦២) (ខ)ផ្តល់នូវ "ការចាប់អារម្មណ៍ជារួម" ថាការជាប់ទាក់ទងជាមួយជម្លោះប្រដាប់អាវុធគឺតម្រូវឱ្យមាន លើកលែងតែឧក្រិដ្ឋកម្មជាក់លាក់ខ្លះដូចជាអាផាថេត(apartheid) និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលបានវិវឌ្ឍក្រោយមកដោយមិនមានជាប់ទាក់ទងយ៉ាងជាក់ស្តែងជាមួយជម្លោះប្រដាប់អាវុធ (ទំព័រ១៦០) និង(គ)បង្ហាញថាគ្មានការអនុវត្តជាទូទៅក្នុងចំណោមរដ្ឋបានកើតមាននៅពេលនេះទេ(ទំព័រ១៦៧ និង១៨៣)។ អនុសញ្ញាអឺរ៉ុបឆ្នាំ១៩៧៤ស្តីអំពីការមិនអាចអនុវត្តបាននៃច្បាប់អាជ្ញាយុកាលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម និងអនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាប និងផ្តន្ទាទោសឧក្រិដ្ឋកម្មអាផាថេត Apartheid (ដែលចូលជាធរមាននៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧៦) មិនផ្តល់ការគាំទ្រចាំបាច់ដល់សេចក្តីស្នើដែលថាភាពជាប់ទាក់ទងគ្នាលែងជាតម្រូវការទៀតហើយត្រឹមឆ្នាំ១៩៧៥ ដល់១៩៧៩(ទំព័រ១៦៧ និង១៦៨)។ *ប៉ុន្តែសូមមើលរឿងក្តីអគ្គព្រះរាជអាជ្ញាតទល់នឹង Eichmann* សំណុំរឿងលេខ 36 I.L.R. 5 (JM 1961) 277-278(S. Ct. 1962) (Isr), aff'd, 36 ILR ។ *Barbie* (សាលាវិនិច្ឆ័យបារាំង (French Court of Cassation) (ផ្នែកព្រហ្មទណ្ឌ) ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៨៨ បោះពុម្ពឡើងវិញនៅក្នុង 100 I.L.R. 331, 336 (1995)) ។ និង*Touvier* (សាលាឧទ្ធរណ៍បារាំងនៅទីក្រុងប៉ារីស (ផ្នែកចោទប្រកាន់ដំបូង ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៩២ បោះពុម្ពឡើងវិញនៅក្នុង 100 I.L.R. 361-63 (1981)) (ដែលភាពជាប់ទាក់ទងគ្នាមិនចាំបាច់តម្រូវឱមានទាក់ទងទៅនិងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវគេចោទប្រកាន់ថាបានប្រព្រឹត្តនៅក្នុងសង្គ្រាមលោកលើកទី២)។ គេសន្និដ្ឋានថាសេចក្តីសម្រេចរបស់តុលាការជាតិនានា មិនអាចចាត់ទុកថាជាសេចក្តីប្រកាសច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តទេ។ ផ្ទុយទៅវិញ គឺនិយមន័យរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងសាលក្រមតុលាការយោធាអន្តរជាតិទេដែលមានតំលៃខ្ពស់ជាង។ សូមមើល Ford ត្រង់ទំព័រ១៤៨។

អំពីលក្ខន្តិកៈទីក្រុងរ៉ូម នៅឆ្នាំ១៩៩៨[28]។

## គ. ការវាយប្រហារត្រូវមានការពាក់ព័ន្ធនឹងអំពើជាច្រើន អនុលោមតាម ឬក៏តាមការជួយសម្រេចគោលនយោបាយរបស់រដ្ឋ ឬ របស់អង្គការចាត់តាំង

១០. លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិតម្រូវឱ្យ "ការវាយប្រហារ" មានការជាប់ពាក់ព័ន្ធជាមួយនឹងអំពើជាច្រើនដែលត្រូវបានប្រព្រឹត្ត "អនុលោមតាម ឬ តាមការជួយសម្រេចគោលនយោបាយរបស់រដ្ឋ ឬ របស់អង្គការចាត់តាំង"[29]។ កិច្ចព្រមព្រៀងយោងលើនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។ ច្បាប់ស្តីពីការបង្កើត អវតក មិនមានចែងអំពីលក្ខខណ្ឌកំណត់នេះទេ ប៉ុន្តែក៏មិនបានបដិសេធចំណុចនេះឡើយ។ ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាតម្រូវថា ភាពមានន័យមិនច្បាស់លាស់នៅក្នុងការបកស្រាយលិខិតុបករណ៍សំខាន់នានា <u>ត្រូវសម្រេចដោះស្រាយជាផលប្រយោជន៍ដល់ជនជាប់ចោទ</u>[30]។ អត្ថិភាពនៃគោលនយោបាយមួយដែលគួសបញ្ជាក់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក៏ជាលក្ខខណ្ឌកំណត់របស់ច្បាប់ទំនៀមអន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ផងដែរ[31]។ ហេតុដូច្នេះហើយ អវតក ត្រូវតែអនុវត្ត

---

[28] សូមមើល Ford ត្រង់ nn 283-287។ សូមមើលផងដែរនូវរបាយការណ៍ចុងក្រោយរបស់គណៈកម្មាធិការតាក់តែងសេចក្តីព្រាង ចុះថ្ងៃទី ១៤ មេសា ១៩៩៨ ឯកសារ UN. Doc. A/CONF.183/2/Add.1, ផ្នែកទី១ (PartI), មាត្រា៥, ទំព័រ២៦ ដែលអត្ថបទនេះត្រូវបានដកស្រង់ដោយ BASSIOUNI ត្រង់ទំព័រ១៩៩។

[29] លក្ខន្តិកៈតុលាការ ICC មាត្រា៧(២)(ក)។ សូមមើលផងដែរ សេចក្តីសម្រេចទទួលយកបទចោទប្រកាន់ក្នុងរឿងក្តី *Katanga* កថាខណ្ឌ ៣៩៦។ ទាក់ទងនឹងការអនុវត្តលក្ខន្តិកៈតុលាការ ICC សូមមើលកថាខណ្ឌ៥ និង៦ *ជើងទំព័រខាងលើ*។

[30] ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា៣៨។ សូមមើលកថាខណ្ឌ៥ និង៦ ជើងទំព័រខាងលើ។

[31] សូមមើលសាលក្រមតុលាការយោធាអន្តរជាតិ កថាខណ្ឌ២៥៤ (ដែលនិយាយយោងទៅលើ "គោលនយោបាយចំពោះអំពើភេរវកម្ម" និង" គោលនយោបាយចំពោះអំពើធ្វើទុក្ខបុកម្នេញ បង្ក្រាប និងសម្លាប់ប្រជាពលរដ្ឋ"។ សូមមើលផងដែរនូវរបាយការណ៍ចុងក្រោយរបស់គណៈកម្មាធិការជំនាញ ដែលបានបង្កើតឡើងដោយអនុលោមទៅតាមសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខលេខ៧៨០(ឆ្នាំ១៩៩២) ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ស/១៩៩៤/៦៧៤ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ ១៩៩៤ អត្ថបទដកស្រង់ក្នុង M. CHERIF BASSIOUNI & PETER MANIKAS ចំណងជើងសៀវភៅ THE LAW OF THE INTERNATIONAL CRIMINAL TRIBUNAL FOR THE FORMER YUGOSLAVIA ("BASSIOUNI & MANIKAS") ត្រង់ទំព័រ ៥៤៣ (រោងពុម្ព Transnational Publishers ឆ្នាំបោះពុម្ព១៩៩៦)។ *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង* Menten ប្រទេសហូឡង់

តម្រូវការគោលនយោបាយនេះ ដើម្បីកុំឲ្យមានការរំលោភបំពានច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា តាមរយៈការខកខានមិនគោរពគោលការណ៍ *វិមតិសង្ស័យ* (*in dubio pro reo*) និងគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់* (*nullum crimen sine lege*)[32]។

## ឃ. ការវាយប្រហារត្រូវបានកើតមានឡើងដោយសារមូលដ្ឋាននៃការរើសអើង

១១. ច្បាប់ស្តីពីការបង្កើត អវតក តម្រូវយ៉ាងច្បាស់លាស់ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពាក់ព័ន្ធនឹងការវាយប្រហារសំដៅប្រឆាំងនឹងប្រជាជនស៊ីវិល ដោយមូលហេតុជាតិ នយោបាយ ជាតិពិន្ទុ ពូជសាសន៍ ឬ សាសនា។ ការកំណត់នេះត្រូវយកមកអនុវត្ត ពីព្រោះ (១) អនុលោមតាមច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រសិនបើច្បាប់ស្តីពីការបង្កើត អវតក (ដែលជាច្បាប់កើតក្រោយកិច្ចព្រមព្រៀង) ផ្តល់ផលប្រយោជន៍ច្រើនជាងដល់ជនជាប់ចោទ ច្បាប់នេះត្រូវយកមកអនុវត្តឈានមុខកិច្ចព្រមព្រៀង ឲ្យស្របតាម គោលការណ៍*នៃ ច្បាប់ណាមានការអនុគ្រោះជាង* (*lex mitior*)[33] (២) អនុលោមតាមច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា វិមតិសង្ស័យ នៅ

---

តុលាការទីក្រុងអាំស្ទែដាំ អង្គជុំនុំជម្រះព្រហ្មទណ្ឌវិសាមញ្ញ បោះពុម្ពឡើងវិញនៅក្នុង 75 I.L.R. ទំព័រ៣៦២-៦៣ (ឆ្នាំ១៩៨១) "ទស្សនៈ 'ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ' ក៏ទាមទារផងដែរ...ថាឧក្រិដ្ឋកម្មដែលចោទជាបញ្ហាបង្កើតបានជាផ្នែកមួយនៃប្រពន្ធ័មួយដែលផ្អែកលើការបំភិតបំភ័យ ឬបង្កើតបានជាការជាប់ពាក់ព័ន្ធទៅក្នុងនយោបាយដែលអនុវត្តដោយគិតទុកជាមុនក្នុងទិសដៅប្រឆាំងនិងក្រុមមនុស្សណាមួយ"។ សូមមើលផងដែរសៀវភៅរបស់ BASSIOUNI ត្រង់ទំព័រ២៤៣-២៦៥, ២៧៧, ៥៥៨ ("សកម្មភាព ឬនយោបាយរបស់រដ្ឋគឺជាចារិកលក្ខណៈសំខាន់នៃ 'ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ'")។ BASSIOUNI & MANIKAS ទំព័រ៥៤៨ (ការរាប់បញ្ចូលការធ្វើទុក្ខបុកម្នេញឲ្យទៅជាអំពើមួយដាច់ដោយឡែកនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងលក្ខន្តិកៈតុលាការICTY "មានន័យជាការយកចេញនូវលក្ខខណ្ឌតម្រូវការនោះ ដែលស្ថិតក្រោម៦(គ)នៃធម្មនុញ្ញតុលាការយោធាអន្តរជាតិ ដែលចែងថាការធ្វើទុក្ខបុកម្នេញនេះបង្កើតជាគោលនយោបាយនៃការធ្វើទុកុខបុកម្នេញ")។ សូមមើលសាលដីកាអង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Kordić & Čerkez* កថាខណ្ឌ៩៨។ សាលដីកាអង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Blaškić* កថាខណ្ឌ១២០។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *Blagojević & Jokić* កថាខណ្ឌ៥៧៦។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *Brđanin* កថាខណ្ឌ១៣៧។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *Limaj* កថាខណ្ឌ២១២ និង ១៨៤ (ស្តីអំពីគោលជំហរនៃច្បាប់ទំនៀមទំលាប់អន្តរជាតិនាពេលបច្ចុប្បន្ន)។

[32] *សូមមើលកថាខណ្ឌ* ៥ និង ៦*ដើងទំព័រខាងលើ*។

[33] *សូមមើល*ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា៣១ ICCPR មាត្រា១៥។ *សូមមើលផងដែរ*កថាខណ្ឌ ៤ ដល់ ៦*ដើងទំព័រខាងលើ*។

ក្នុងការបកស្រាយលិខិតុបករណ៍សំខាន់ ត្រូវដោះស្រាយដោយផ្តល់ប្រយោជន៍ដល់ជនជាប់ចោទ[34] (៣) វិធានទូទៅគឺថា ច្បាប់ស្តីពីការបង្កើត អវតក មានឧត្តមានុភាពលើកិច្ចព្រមព្រៀង (ចំពោះអ្វីដែលផ្ទុយនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលមានឧត្តមានុភាពលើលិខិតុបករណ៍សំខាន់)[35] និង (៤) ច្បាប់ទំនៀមអន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ពិតជាបានរួមបញ្ចូលនូវលក្ខខណ្ឌតម្រូវខាងការរើសអើង[36]។ ច្បាប់ទំនៀមអន្តរជាតិបានបន្តថា ការវាយប្រហារដោយសារការរើសអើង ត្រូវតែមានភស្តុតាងបញ្ជាក់ ដើម្បីបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អវតក[37] ។

**ខ. មានតែអំពើជាមូលដ្ឋានដែលត្រូវបានកំណត់ច្បាស់លាស់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ទំនៀមអន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ប៉ុណ្ណោះ**

---

[34] ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា៣៨។ *សូមមើលផងដែរ* កថាខណ្ឌ៣, ៥ និង៦ *ជើងទំព័រខាងលើ*។

[35] *សូមមើល*កថាខណ្ឌ៥ និង ៦ *ជើងទំព័រខាងលើ*។

[36] គេលើកឡើងថា *ទស្សនៈច្បាប់ (opinio juris)* ចាប់តាំងពីឆ្នាំ១៩៩៣មកម្លេះ តម្រូវថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវតែប្រព្រឹត្ត "នៅលើហេតុផលជាតិ នយោបាយ ជាតិពន្ធ ជាតិសាសន៍ ឬសាសនា"។ *សូមមើល*របាយការណ៍របស់អគ្គលេខាធិការ នៅកថាខណ្ឌ២នៃសេចក្តីសម្រេចចិត្រលេខ៨០៨ (ឆ្នាំ១៩៩៣)របស់ក្រុមប្រឹក្សាសន្តិសុខ និងឧបសម្ព័ន្ធរបស់វា ឯកសារអង្គការសហប្រជាជាតិលេខ U.N. Doc. S/25704 កថាខណ្ឌ៤៨។ *សូមមើលផងដែរ* Provisional Verbatim Record នៃកិច្ចប្រជុំលើកទី៣២១៧ ឯកសារអង្គការសហប្រជាជាតិលេខ U.N.Doc. S/PV. 3217 (ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៣) ១១(សេចក្តីថ្លែងការណ៍របស់ប្រទេសបារាំង ដោយរាយនូវហេតុផលជាតិ ជាតិពន្ធ ជាតិសាសន៍ និងសាសនា) ១៦(សេចក្តីថ្លែងការណ៍របស់សហរដ្ឋអាមេរិច ដោយរាយនូវហេតុផលជាតិ នយោបាយ ជាតិពន្ធ ជាតិសាសន៍ យេនឌ័រនិងសាសនា) និង៤៥(សេចក្តីថ្លែងការណ៍របស់សហព័ន្ធរុស្ស៊ី ដោយរាយនូវហេតុផលជាតិ នយោបាយ ជាតិពន្ធ សាសនា ឬហេតុផលផ្សេងៗទៀត)។ *សូមមើលផងដែរ* សៀវភៅរបស់WILLIAM SCHABAS ដែលមានចំណងជើងថា៖ THE UN INTERNATIONAL CRIMINAL TRIBUNALS: THE FORMER YUGOSLAVIA, RWANDA AND SIERRA LEONE ទំព័រ១៩៦-១៩៨ (គ្រឹស្ថានបោះពុម្ព Cambridge ឆ្នាំ២០០៦)។ សៀវភៅរបស់ BASSIOUNI & MANIKAS ទំព័រ៥៤៣។

[37] ការណែនាំចំពោះការបកស្រាយច្បាប់ស្តីពីការបង្កើត[អ.វ.ត.ក] ទាក់ទងនឹងលក្ខណៈតម្រូវមានដែលមានការរើសអើង អាចយកពីយុត្តិសាស្ត្រតុលាការ ICTR។ មាត្រា៣នៃលក្ខន្តិកៈតុលាការ ICTR ដូចគ្នានឹងច្បាប់ស្តីពីការបង្កើត[អ.វ.ត.ក]ដែរ គឺកំហិតយុត្តាធិការចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតែចំពោះអំពើទាំងឡាយណា ដែលប្រព្រឹត្តឡើងជាផ្នែកនៃការវាយប្រហារទូលំទូលាយនិងជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិលដោយហេតុផលរើសអើង។ *សូមមើលរឿងក្តីរដ្ឋអាជ្ញាតទល់នឹង Akayesu*, សំណុំរឿងលេខ ICTR-96-4-A, សាលក្រមថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ៤៦៧-៤៦៨។

**ដែលអាចបង្កើតជាការរំលោភលើមាត្រា ៥ នៃច្បាប់ស្ដីពីការបង្កើត អវតក**

១២. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនមាននៅក្នុងច្បាប់ជាតិនៃព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ទេ[38]។ ប្រសិនបើ កសចស យល់ឃើញថា ខ្លួនមានយុត្តាធិការក្នុងការអនុវត្តឧក្រិដ្ឋកម្មទាំងអស់នេះ ច្បាប់ដែលអាចអនុវត្តបានត្រូវតែស្របជាមួយនឹងច្បាប់ទំនៀមអន្តរជាតិ ពីឆ្នាំ ១៩៧៥ ដល់ ៧៩[39]។ ហេតុដូច្នេះហើយ និយមន័យនៃអំពើជាមូលដ្ឋានដែលអាចអនុវត្តនៅ អវតក ក៏ត្រូវស្របជាមួយនឹងច្បាប់ទំនៀមអន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ផងដែរ។ លើសពីនេះទៀត មិនមែនរាល់បទល្មើសទាំងឡាយដែលបានចែងនៅក្នុងមាត្រា ៥ នៃ ច្បាប់ស្ដីពីការបង្កើត អវតក[40] និងនៅក្នុងមាត្រា ៧ នៃលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ[41] ឬច្បាប់ផ្សេងពីនេះ ដែលត្រូវបានអះអាងថាទុកសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[42] ត្រូវបានចែងនៅក្នុងការកំណត់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុង ច្បាប់ទំនៀមអន្តរជាតិ ពីឆ្នាំ១៩៧៥ ដល់១៩៧៩ នោះឡើយ។ បទល្មើសទាំងនេះ ត្រូវតែដកចេញពីយុត្តាធិការរបស់ អវតក ពាក់ព័ន្ធជាមួយនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[43]។

**ខ. ប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" មិនអាចអនុវត្តនៅ អវតក ខ ប្រសិនបើប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" អាចអនុវត្តបាន នោះការអនុវត្តត្រូវតែកម្រិតព្រំដែន <u>ជាដំបូង</u> ត្រឹមអំពើទាំងឡាយដែលត្រូវបាន**

---

[38] មិនមានការនិយាយអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាប្រភេទផ្សេងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦នោះទេ។ *សូមមើល* ពាក្យសុំលើកទីមួយអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

[39] *សូមមើល*កថាខណ្ឌ៥*ជើងទំព័រខាងលើ*។ *សូមមើលផងដែរ* សាលដីកា JCE កថាខណ្ឌ ៥៨ ។

[40] ជាឧទាហរណ៍ ការរំលោភសេពសន្ថវៈ និង ការដាក់ឃុំឃាំងនៅក្នុងគុក ។

[41] ជាឧទាហរណ៍ ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ។

[42] *សូមមើលរឿងក្ដីអៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹងការរៀបការដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ D268/2, ERN: 00417249-00417254។

[43] *សូមមើលផងដែរ* ផ្នែកច *ជើងទំព័រខាងក្រោម*។

### សម្គាល់ឃើញយ៉ាងច្បាស់លាស់ នៅក្នុងឆ្នាំ ១៩៧៥ដល់ ១៩៧៩ អញ្ជើងឯង ដោយយោងទៅរកបទដ្ឋានច្បាប់ព្រហ្មទណ្ឌ <u>តែកាលនោះប៉ុណ្ណោះ</u> ដែលដំណើរការអាចធ្វើទៅបានចំពោះគោលការណ៍នៃការបកស្រាយ *ដូចៗគ្នាហ្នឹង* ដែលមិនមានរៀបរាប់ (*ejusdem generis* principle of interpretation)

១៣. ដោយសារតែតុលាការប្រទេសកម្ពុជាបានផ្អែកលើប្រព័ន្ធច្បាប់រ៉ូម៉ាណូហ្សែកម៉ានិក (civil law) ទើប អវតក មានតែយុត្តាធិការលើបទឧក្រិដ្ឋទាំងឡាយដែលច្បាប់បានប្រកាសយ៉ាងច្បាស់លាស់ប៉ុណ្ណោះ[44]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ក្នុងរឿងក្តី Stakic បានថ្លែងបញ្ជាក់ថា "ខ្លួនពិចារណាឃើញថា លំដាប់ធំទូលាយដ៏មានសក្តានុពលនៃអំពើអមនុស្សធម៌ផ្សេងទៀតអាចលើកឡើងនូវកង្វល់នានាចំពោះការរំលោភបំពានដែលអាចកើតមានឡើងលើគោលការណ៍*គ្មានបទល្មើស (nullum crimen* principle")។[45] កង្វះភាពជាក់លាក់ជាប្រចាំនៃ "អំពើអមនុស្សធម៌ផ្សេងទៀត" ក៏ត្រូវបានបង្ហាញតាមរយៈវិធីសាស្ត្រដែលមិនស៊ីសង្វាក់គ្នាជាមួយនឹងការបកស្រាយនៅតុលាការ ICTY[46]។ ដោយសារតែកង្វះភាពប្រាកដប្រជានេះ ជាបញ្ហាដែលមានភាពស្រួចស្រាវ

---

[44] មាត្រា៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ចែងថា៖ "បទល្មើសណាបានប្រព្រឹត្តមុនបទបញ្ញត្តិរបស់ច្បាប់ បទល្មើសនោះមិនអាចត្រូវនិគ្រោះដោយទោសរបស់ច្បាប់ដែលទើបនឹងបញ្ញត្តិថ្មីនេះបានទេ"។ (ការបកប្រែក្រៅផ្លូវការ)

[45] សាលដីកាលើបណ្តឹងឧទ្ធរណ៍ Kordic & Cerkez កថាខណ្ឌ ១១៧ ។ អង្គជំនុំជំរះសាលាដំបូងរបស់ICTY ក្នុងរឿងក្តីStakic បានគូសចំនាំថា" អំពើអមនុស្សធម៌ផ្សេងទៀត"ដែលជាប្រភេទមួយ "អាចត្រូវបានគេពិចារណាថាមានភាពខ្វះខាតនូវភាពជាក់ច្បាស់ ភាពត្រឹមត្រូវនិងភាពទៀងទាត់" ដែលវាជាការរំលោភបំពានទៅលើគោលការណ៍នៃភាពច្បាស់លាស់។ សូមមើល *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Stakić*, សំណុំរឿងលេខ IT-97-24-T, សេចក្តីសម្រេចតាមវិធាន៩៨ស្ទួន លើសំណើសុំអោយចេញសាលក្រមសម្រេចឱ្យរួចផុតពីបទចោទ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០២ កថាខណ្ឌ១៣១។ *ប៉ុន្តែសូមមើលរឿងក្តីរដ្ឋអាជ្ញាតទល់នឹង Stakić*, សំណុំរឿងលេខ IT-97-24-A សាលដីកា ថ្ងៃទី២២ ខែមិនា ឆ្នាំ២០០៦ ("សាលដីកាអង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Stakić*") កថាខណ្ឌ៣១៥។ ចំពោះចំនុចនេះអង្គជំនុំជម្រះតុលាការកំពូលច្រានចោលអង្គជំនុំជម្រះសាលាដំបូង ហើយសន្និដ្ឋានថា"អំពើអមនុស្សធម៌ផ្សេងទៀត" បង្កើតបានជា ផ្នែកមួយនៃច្បាប់ទំនៀមទំលាប់អន្តរជាតិ ។ ប៉ុន្តែសូមធ្វើការអះអាងថា នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល (Civil Law System) ដូចនៅ អ.វ.ត.ក. ទស្សនៈរបស់ អង្គជំនុំជម្រះតុលការកំពូលក្នុងរឿងក្តី Kordic & Cerkez និងរបស់ អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *Stakić* ត្រូវតែទទួលការគាំទ្រ ។

[46] នៅក្នុងការព្យាយាមបង្កើតវិសាលភាពនៃ"អំពើអមនុស្សធម៌ដ៏ទៃទៀត" អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *Kupreškić* នៅតុលាការ ICTY បានកំណត់មាត្រដ្ឋានអន្តរជាតិស្តីអំពីសិទ្ធិមនុស្ស "ដូចជាមាត្រដ្ឋានដែលមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨ និងកត្តិកាសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៦៦" ដែលមានចែងការ

ជាពិសេសនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល (Civil Law System) ដូចប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ជាប្រភេទមួយ រំលោភបំពានលើលក្ខខណ្ឌតម្រូវដែលថា បទឧក្រិដ្ឋនានាត្រូវតែមានប្រកាសយ៉ាងច្បាស់លាស់ ហើយឧក្រិដ្ឋទាំងនោះមិនអាចយកមកអនុវត្តនៅ អវតក បានទេ។

១៤. ប្រសិនបើប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" អាចយកមកអនុវត្តបាន វាត្រូវតែបានកម្រិតព្រំដែនត្រឹមតែអំពើទាំងឡាយ "មានលក្ខណៈប្រហាក់ប្រហែលគ្នាណាមួយ ដែលបង្កដោយចេតនានូវទុក្ខសោកក្រៃលែង ឬ បង្ករបួសស្នាមធ្ងន់ធ្ងរដល់រាងកាយ ឬ ចំពោះសុខភាពផ្លូវចិត្ត ឬ ផ្លូវកាយ"[47]។ ទោះបីជាលក្ខន្តិកៈរបស់ តុលាការ *ចំពោះកិច្ច* ទាំងឡាយ (ដូចជាច្បាប់ស្តីពីការបង្កើត អវតក) គ្មានការកំណត់ឱ្យបានច្បាស់លាស់ក្តី ក៏យុត្តិសាស្ត្ររបស់តុលាការទាំងនេះបានកម្រិតព្រំដែននៃការបកស្រាយរបស់ខ្លួនប្រហាក់ប្រហែលគ្នា[48]។ យុត្តិសាស្ត្ររបស់តុលាការ ICTY ផ្តល់យោបល់ថា <u>ជាបឋម</u> តុលាការគួរអនុវត្តតាម "<u>និយាមច្បាប់ព្រហ្មទណ្ឌ</u>" ដើម្បីកំណត់អំពីព្រំដែននៃ

---

កំណត់ដែលអាចប្រមើមើលឃើញជាមុននូវអ្វីដែលបង្កើតបានជា"អំពើអមនុស្សធម៌ដ៏ទៃទៀត" (សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *Kupreškić* កថាខណ្ឌ ៥៦៦)។ វិធីនេះត្រូវបានរិះគន់ដោយអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *Stakić* នៅតុលាការICTY ថា៖ "អង្គជំនុំជម្រះសាលាដំបូងសូមរមលឹកឡើងវិញអំពីរបាយការណ៍របស់អគ្គលេខា ដែលតាមរយៈរបាយការណ៍នេះ 'ការអនុវត្តនូវគោលការណ៍គ្មានច្បាប់ គឺគ្មានបទល្មើស *(nullum crimen sine lege)* តម្រូវថាតុលាការអន្តរជាតិនេះត្រូវអនុវត្តវិធាននៃច្បាប់មនុស្សធម៌អន្តរជាតិដែលច្បាស់ណាស់វាជាផ្នែកមួយនៃច្បាប់ទំនៀមទំលាប់។' ដូច្នេះហើយ អង្គជំនុំជម្រះសាលាដំបូងស្នាក់ស្ទើក្នុងការប្រើជាស្វ័យប្រវត្តិនូវច្បាប់សិទ្ធិមនុស្សបែបនេះថាជាមូលដ្ឋាននៃបទដ្ឋានច្បាប់ព្រហ្មទណ្ឌ ដូចជាករណីមួយដែលចែងក្នុងមាត្រា៥(ឈ)នៃលក្ខន្តិកៈ... <u>បទដ្ឋាននៃច្បាប់ព្រហ្មទណ្ឌជានិច្ចកាលត្រូវតែផ្តល់ដល់អង្គជំនុំជម្រះនូវឧបករណ៍សមរម្យមួយសម្រាប់ជាមូលដ្ឋានក្នុងការថ្លឹងថ្លែងការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់សម្រាប់គោលបំណងនៃមាត្រា៥(ឈ)ដើម្បីឱបុគ្គលគ្រប់រូបដឹងថាអ្វីជាការប្រព្រឹត្តដែលគេអនុញ្ញាត ហើយអ្វីដែលគេមិនអនុញ្ញាត</u> " (រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Stakic សំនុំរឿងលេខ IT-97-24-T,សាលក្រម (សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *Stakić)* កថាខណ្ឌ ៧២១។ សូមមើលផងដែរនូវ សាលក្រមជំនុំជម្រះក្នុងរឿង Blagojevic & Jokic កថាខណ្ឌ ៦២៥។

[47] លក្ខន្តិកៈតុលាការ ICC មាត្រា៧(K)។

[48] *សូមមើល*សាលដីការអង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Kordić & Čerkez* កថាខណ្ឌ១១៧។ *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Naletilić & Martinović,* សំណុំរឿងលេខ IT-98-34-T, សាលក្រមថ្ងៃទី៣១ ខែមិនា ឆ្នាំ២០០៣ កថាខណ្ឌ២៤៧។ *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Bagilishema,* សំណុំរឿងលេខ ICTR-95-1A-T, សាលក្រមថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ៨១-៨២។

"អំពើអមនុស្សធម៌ផ្សេងៗទៀត"[49]។ ដោយសារតែកង្វះភាពច្បាស់លាស់ជាប់ប្រចាំ <u>បន្ទាប់មក</u> ទើបអាចប្រើប្រាស់ វិធាននៃការបកស្រាយ *ដូចៗគ្នាហ្នឹងដែលមិនបានរៀបរាប់*[50] (*ejusdem generis* rule of interpretation)[51] ។ គេបានស្នើសុំឱ្យពិចារណាថា វិធីសាស្ត្រនៃការបកស្រាយនេះស៊ីសង្វាក់គ្នានឹងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ក៏ដូចជាកិច្ចព្រមព្រៀង ដូច្នេះហើយ វិធីសាស្ត្រនេះគួរត្រូវបានប្រកាន់យកដោយ អវតក។

១៥. ប្រសិនបើបទឧក្រិដ្ឋនានា ដូចខាងក្រោម ត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅ អវតក បទឧក្រិដ្ឋទាំងនេះគួរត្រូវកំណត់ថាជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ហើយប្រសិនបើ

---

[49] សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *Stakić* កថាខណ្ឌ៧២១។ *សូមមើល* n. ៤៧ *ជើងទំព័រខាងលើ*។ *សូមមើលផងដែររឿងក្តីរដ្ឋអាជ្ញាតទល់នឹង Jelisić* សំណុំរឿងលេខ IT-95-10-T សាលក្រមថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ៥២៖ "គឺជាការសមរម្យក្នុងការរំលឹកឡើងវិញនូវជំហររបស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *Čelebići* ដែលថ្លែងថាអត្ថន័យនៃការធ្វើបាបយ៉ាងសាហាវដែលមានចែងក្នុងមាត្រា៣នៃលក្ខន្តិកៈនោះ[ការរំលោភច្បាប់ ឬទម្លាប់ច្បាប់] 'មានអត្ថន័យស្មើគ្នា... នឹងការធ្វើបាបយ៉ាងអមនុស្សធម៌ទាក់ទងនឹងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ។' ដូចគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងចាត់ទុកថា អត្ថន័យនៃការធ្វើបាបយ៉ាងសាហាវដែលមានចែងក្នុងមាត្រា៣ និងអត្ថន័យនៃការធ្វើបាបយ៉ាងអមនុស្សធម៌ដែលមានចែងក្នុងមាត្រា៥នៃលក្ខន្តិកៈ[ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ] មានអត្ថន័យផ្នែកច្បាប់ដូចគ្នា។" ជាពិសេសដោយពិចារណានូវការតម្រូវឱ្យមានភាពជាប់ទាក់ទងគ្នាជាមួយជម្លោះប្រដាប់អាវុធ នៅមាននៅឡើយក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងចន្លោះឆ្នាំ១៩៧៥-៧៩។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី Blagojevic & Jokic កថាខណ្ឌ ៦២៥។ ផ្ទុយទៅវិញ សព្វថ្ងៃនេះឧក្រិដ្ឋប្រឆាំងមនុស្សជាតិ "លែងជាប់ទាក់ទងនឹងច្បាប់សង្គ្រាមទៀតហើយ ប៉ុន្តែជាប់ទាក់ទងនឹងច្បាប់សិទ្ធមនុស្ស។" យោងតាម Kai Ambos & Steffen Wirth, *The Current Law of Crimes Against Humanity: An Analysis of UNTAET Regulation 15/2000,*13 Criminal Law Forum 1, 24, (2002)។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី Blagojevic & Jokic កថាខណ្ឌ ៦២៥។

[50] "គោលការណ៍ *Ejusdem generis* ត្រូវបានគេឱនិយមន័យជា "វិធានគ្រឹះមួយដែលថា នៅពេលដែលពាក្យឬឃ្លាទូទៅមួយដែលអមដោយបញ្ជីមួយរាយនាមមនុស្ស ឬវត្ថុជាក់លាក់ ពាក្យ ឬឃ្លាទូទៅមួយនោះនឹងបានត្រូវគេបកស្រាយដោយរាប់បញ្ចូលតែមនុស្ស ឬវត្ថុដូចគ្នានឹងមនុស្ស ឬវត្ថុដែលមានរាយក្នុងតារាងតែប៉ុណ្ណោះ។" ដកស្រង់ពីវចនានុក្រម BLACK"S LAW DICTIONARY 535 (7th ed. 1999)។

[51] *សូមមើល*សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *Kupreškić* កថាខណ្ឌ៥៦៤ និង៥៦៦។ សាស្ត្រាចារ្យ Bassiouni ក៏បានព្រមានអំពីគ្រោះថ្នាក់ដែលមានជាប់ជាមួយវិធីសាស្ត្រ *ejusdem generis* ក្នុងប្រព័ន្ធច្បាប់ common law, ដើម្បីយកមកបកស្រាយ"អំពើអមនុស្សធម៌ដ៏ទៃទៀត" ដោយធ្វើការកត់សំគាល់ថា "វាប្រហែលជាត្រូវគេចាត់ទុកថាជាការរំលោភ "គោលការណ៍នីត្យានុកូលភាព" ប្រសិនបើការបកស្រាយសទិសភាព មិនត្រូវបានកម្រិតច្បាស់លាស់ទេនោះ" BASSIOUNI 330។

"អំពើអមនុស្សធម៌ផ្សេងៗទៀត" អាចយកមកអនុវត្តបាន នោះអំពើទាំងនេះគួរត្រូវបានកំណត់ក្នុងរបៀបដូចបានថ្លែងបញ្ជាក់នៅក្នុងឯកសារនេះ។

**i. អំពើរំលោភសេពសន្ថវៈ**

១៦. *ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានរៀបរាប់* អំពើរំលោភសេពសន្ថវៈមិនត្រូវបានរាយបញ្ជីនៅក្នុង (ក) ធម្មនុញ្ញតុលាការយោធាអន្តរជាតិ (ខ) ធម្មនុញ្ញឆ្នាំ ១៩៤៦ របស់តុលាការយោធាអន្តរជាតិសម្រាប់ជ្រោយបូព៌ា (គ) គោលការណ៍ Nuremberg (ឃ) សេចក្តីព្រាងក្រម ឆ្នាំ ១៩៥៤ ស្តីពីបទល្មើសនានាប្រឆាំងនឹងសន្តិភាព និង សន្តិសុខរបស់មនុស្សជាតិ ឬ (ង) អនុសញ្ញាឆ្នាំ ១៩៦៨ ស្តីពីភាពមិនអាចអនុវត្តបាននៃអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ[52]។ ការមិនចែងពីអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងលិខិតុបករណ៍ទាំងអស់នេះ បង្ហាញថា អំពើនេះមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចរៀបរាប់នៅក្នុងច្បាប់ទំនៀមអន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ឡើយ។ ដូច្នេះ ដោយមិនធ្វើឱ្យប៉ះពាល់ដល់គោលជំហររបស់សហមេធាវីការពារក្តី ដែលថា "អំពើអមនុស្សធម៌ផ្សេងទៀត" ជាប្រភេទមួយ មិនអាចយកមកអនុវត្តបាន[53] នោះការចោទពីបទរំលោភសេពសន្ថវៈណាក៏អាចរំលោភលើមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អវតក ដែរ ប្រសិនថា (ក) "អំពើអមនុស្សធម៌ផ្សេងទៀត" នោះជាប្រភេទមួយអាចយកមកអនុវត្តបាន និង (ខ) អំពើរំលោភសេពសន្ថវៈរួមផ្សំជា "អំពើអមនុស្សធម៌ផ្សេងទៀត" អំឡុងឆ្នាំ ១៩៧៥ ដល់ ១៩៧៩។

**ii. ការដាក់ឃុំឃាំងនៅក្នុងពន្ធនាគារ**

១៧. *ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានរៀបរាប់* ការដាក់ឃុំឃាំងនៅក្នុងពន្ធនាគារមិនត្រូវបានរាយបញ្ជីនៅក្នុង (ក) ធម្មនុញ្ញតុលាការយោធាអន្តរជាតិ (ខ) ធម្មនុញ្ញឆ្នាំ ១៩៤៦ របស់

---

[52] សូមធ្វើការអះអាងថា ការរាប់បញ្ចូលអំពើ រំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុង Control Council Law No.10 មិនមានលក្ខណៈដាច់ខាតនោះទេ។ តុលាការសម្ព័ន្ធមិត្រ និងតុលាការអាល្លឺម៉ង់ដែលអនុវត្តច្បាប់នេះគឺជា "តុលាការជាតិដែលជាធម្មតាប្រើប្រាស់ច្បាប់ជាតិ (ច្បាប់ក្នុងស្រុក) ដែលការពិតនោះបានបញ្ចូលនូវបទបញ្ញត្តិនានាដែលមានដើមកំណើតចេញមកពីអាជ្ញាធរដែលត្រួតត្រាប្រទេសនោះ។" Schwelb ទំព័រ២១៨-២១៩។

[53] *សូមមើលកថាខណ្ឌ ១៣ ខាងលើ។*

តុលាការយោធាអន្តរជាតិសម្រាប់ជ្រោយបូព៌ា (គ) គោលការណ៍ Nuremberg (ឃ) សេចក្តីព្រាងក្រម ឆ្នាំ ១៩៥៤ ស្តីពីបទល្មើសនានាប្រឆាំងនឹងសន្តិភាព និង សន្តិសុខរបស់មនុស្សជាតិ ឬ (ង) អនុសញ្ញាឆ្នាំ ១៩៦៨ ស្តីពីភាពមិនអាចអនុវត្តបាននៃអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ[54]។ ការមិនចែងពីអំពើដាក់ឃុំឃាំងក្នុងពន្ធនាគារថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងលិខិតុបករណ៍ទាំងអស់នេះ បង្ហាញថា អំពើនេះមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចរៀបរាប់នៅក្នុងច្បាប់ទំនៀមអន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ឡើយ។ ដូច្នេះ ដោយមិនធ្វើឱ្យប៉ះពាល់ដល់គោលជំហររបស់សហមេធាវីការពារក្តី ដែលថា "អំពើអមនុស្សធម៌ផ្សេងទៀត" ជាប្រភេទមួយ មិនអាចយកមកអនុវត្តបាន[55] នោះការចោទពីបទរំលោភសេពសន្ថវៈណាក៏អាចរំលោភលើមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អវតក ដែរ ប្រសិនថា (ក) "អំពើអមនុស្សធម៌ផ្សេងទៀត"នោះ ជាប្រភេទមួយអាចយកមកអនុវត្តបាន និង (ខ) អំពើរំលោភសេពសន្ថវៈរួមផ្សំជា "អំពើអមនុស្សធម៌ផ្សេងទៀត" អំឡុងឆ្នាំ ១៩៧៥ ដល់ ១៩៧៩។

### iii. ការងារដោយបង្ខំ

១៨. ពុំមានលិខិតុបករណ៍អន្តរជាតិណាមួយដែលចុះកាលបរិច្ឆេទមុន ឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ដែលរៀបរាប់ពីការធ្វើពលកម្មដោយបង្ខំ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ ហើយការធ្វើការដោយបង្ខំនេះក៏មិនត្រូវបានចាត់ជាបទឧក្រិដ្ឋក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ អញ្ចឹងឡើយ[56]។ ការងារដោយបង្ខំត្រូវបានញែកដាច់ពី "ទាសកម្ម"។ ការយកធ្វើជាទាសករ ក្តោបព័ទ្ធធាតុផ្សំមួយ

[54] សូមធ្វើការអះអាងថាការការរួមបញ្ចូលអំពើឃុំឃាំង ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុង Control Council Law No. 10 គឺមិនមានលក្ខណៈដាច់ខាតនោះទេ។ *សូមមើល*កំណត់សំគាល់ ៥២ *ជើងទំព័រខាងលើ*។

[55] *សូមមើលកថាខណ្ឌ*១៣ *ជើងទំព័រខាងលើ*។

[56] *សូមមើល* Schwelb នៅទំព័រ១៩២។ គាត់ធ្វើការកត់សំគាល់ថា៖ "ប៉ុន្តែអំណាចរបស់អ្នកធ្វើសង្គ្រាមមិនត្រូវបានគេហាមឃាត់មិនឱ្យនិរទេសនូវជនជាតិរបស់ខ្លួនឱ្យទៅធ្វើការដោយបង្ខំនោះទេ។ តាមការបកស្រាយនេះ មានតែការធ្វើឱ្យជនជាតិរបស់ខ្លួនស្ថិតក្នុង សភាពទាសភាពពិតប្រាកដ ទើបចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"។ *សូមមើលផងដែរ*សាលដីកាអង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Blaskić* កថាខណ្ឌ៥៩៧ (ដោយកត់សំគាល់ថាការបង្ខំឱ្យធ្វើការមិនមែនសុទ្ធតែខុសច្បាប់នោះទេ)។

នៃភាពជាម្ចាស់លើមនុស្សណាម្នាក់ រីឯការធ្វើពលកម្មដោយបង្ខំមិនដូច្នេះទេ[57]។ ដូចនេះ ដោយមិនឱ្យប៉ះពាល់ដល់ជំហររបស់សហមេធាវីការពារក្តី ដែលថា "អំពើអមនុស្សធម៌ផ្សេងទៀត" ជាប្រភេទមួយមិនអាចយកមកអនុវត្តបាន[58] នោះការចោទពីបទពលកម្មដោយបង្ខំណាក៏អាចរំលោភលើមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អវតក ប្រសិនថា (ក) "អំពើអមនុស្សធម៌ផ្សេងទៀត" ជាប្រភេទមួយ អាចយកមកអនុវត្តបាន និង (ខ) ការធ្វើពលកម្មដោយបង្ខំរួមផ្សំជា "អំពើអមនុស្សធម៌ ផ្សេងទៀត" ក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩។

### iv. អំពើទារុណកម្ម

១៩. *ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានរៀបរាប់* ការធ្វើទារុណកម្ម មិនត្រូវបានរាយបញ្ជីនៅក្នុង (ក) ធម្មនុញ្ញតុលាការយោធាអន្តរជាតិ (ខ) ធម្មនុញ្ញឆ្នាំ ១៩៤៦ របស់តុលាការយោធាអន្តរជាតិសម្រាប់ជ្រោយបូព៌ា (គ) គោលការណ៍ Nuremberg (ឃ) សេចក្តីព្រាងក្រម ឆ្នាំ ១៩៥៤ ស្តីពីបទល្មើសនានាប្រឆាំងនឹងសន្តិភាព និង សន្តិសុខរបស់មនុស្សជាតិ ឬ (ង) អនុសញ្ញាឆ្នាំ ១៩៦៨ ស្តីពីភាពមិនអាចអនុវត្តបាននៃអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ[59]។ ការមិនចែងពីការធ្វើទារុណកម្មជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងលិខិតុបករណ៍ទាំងអស់នេះ បង្ហាញថា ការធ្វើទារុណកម្មមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានចែងនៅក្នុងច្បាប់ទំនៀមអន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ឡើយ។ ដូច្នេះ ដោយមិនធ្វើឱ្យប៉ះពាល់ដល់គោលជំហររបស់សហមេធាវីការពារក្តី ដែលថា "អំពើអមនុស្សធម៌ផ្សេងទៀត" ជាប្រភេទមួយមិនអាចយកមកអនុវត្តបាន[60] នោះការចោទពីអំពើទារុណកម្មណាក៏អាចរំលោភលើមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អវតក ប្រសិនថា (ក) "អំពើអមនុស្សធម៌ផ្សេង

---

[57] *ឧទាហរណ៍ សូមមើល*លក្ខន្តិកៈតុលាការ ICC មាត្រា៧(២)(គ)។ *សូមមើលផងដែរ*និយមន័យនៃពាក្យ "ការធ្វើឱ្យទៅជាទាសករ" នៅក្នុង *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Kunarac et al.,* សំណុំរឿងលេខ IT-96-23 & 23/1 សាលក្រមថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ២00១ កថាខណ្ឌ៥៤២-៥៤៣។

[58] *សូមមើលកថាខណ្ឌ* ១៣ *ខាងលើទំព័រខាងលើ*។

[59] សូមធ្វើការអះអាងថាការការរួមបញ្ចូលការធ្វើទារុណកម្ម ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុង Control Council Law No. 10 គឺមិនមានលក្ខណៈដាច់ខាតនោះទេ។ *សូមមើល*កំណត់សំគាល់ ៥២ *ជើងទំព័រខាងលើ*។

[60] *សូមមើលកថាខណ្ឌ១៣ ជើងទំព័រខាងលើ*។

ទៀត"នោះ ជាប្រភេទអាចយកមកអនុវត្តបាន និង (ខ) ការធ្វើទារុណកម្មផ្សំជា "អំពើអមនុស្សធម៌ផ្សេងទៀត" ក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩។

២០. ពាក់ព័ន្ធនឹងធាតុផ្សំទាំងឡាយនៃអំពើទារុណកម្ម អង្គបុរេជំនុំជម្រះបានស្វែងរកគោលការណ៍ណែនាំពីសេចក្តីប្រកាសស្តីពីកិច្ចការពារមនុស្សគ្រប់រូបឱ្យរួចពីអំពើទារុណកម្ម ឬ ប្រព្រឹត្តិកម្ម ឬ ទណ្ឌកម្ម ដែលឃោរឃៅ អមនុស្សធម៌ ឬ ដែលបន្ទាបបន្ថោក ដែលត្រូវបានអនុម័តដោយសេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៣៤៥២ (xxx) ថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ១៩៧៥ ("សេចក្តីប្រកាសស្តីពីអំពើទារុណកម្ម") និង អនុសញ្ញា ឆ្នាំ ១៩៨៤ ស្តីពីការប្រឆាំងនឹងអំពើទារុណកម្ម និង ប្រព្រឹត្តិកម្ម និង ទណ្ឌកម្ម ឃោរឃៅ អមនុស្សធម៌ ឬ ដែលបន្ទាបបន្ថោកផ្សេងៗ ("CAT")[61]។ យ៉ាងណាក្តី សេចក្តីសម្រេចរបស់មហាសន្និបាតគ្មានអំណាច ឬសិទ្ធិក្នុងការប្រកាស ឬកែប្រែទស្សនាទាននានាអោយទៅជាច្បាប់ទំនៀមអន្តរជាតិបានឡើយ និង ហេតុដូច្នេះហើយឯកសារទាំងនេះមិនចងកាតព្វកិច្ចផ្លូវច្បាប់ឡើយ[62]។ លើសពីនេះទៀត សេចក្តីថ្លែងការណ៍ពីអំពើទារុណកម្មនោះ មិនមែនជាសេចក្តីប្រកាសអំពីច្បាប់ទំនៀមអន្តរជាតិក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ឬ ថានិយមន័យនៃអំពើទារុណកម្មដូចមានចែងនៅក្នុងអនុសញ្ញា CAT មិនអាចអនុវត្តបាននោះឡើយ[63]។ ក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ អនុសញ្ញា CAT មិនទាន់មានអត្ថិភាពនៅឡើយទេ[64]។ ការអនុវត្តនិយម

---

[61] *រឿងក្តីកាំង ហ្កេកអ៊ាវ ហៅ "ឌុច"* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ប.ជ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ D99/3/42, ERN: 0249846-0249887 កថាខណ្ឌ៦៣-៦៧។

[62] *សូមមើល* Hugh Thirlway, *The Sources of International Law,* in INTERNATIONAL LAW 115, 124 (M. Evans, ed., គ្រឹះស្ថានបោះពុម្ព Oxford University Press, 2006) (ដោយថ្លែងថាសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតត្រូវបានគេចាត់ទុកថាជាភស្តុតាងនៃ *ទស្សនៈច្បាប់* *(opinio juris)* ប៉ុន្តែមិនមែនជាអំពើនានានៃការអនុវត្តរបស់រដ្ឋនោះទេ)។

[63] *សូមមើល* Hans Danelius, *Convention Against Torture and Other Cruel, Inhuman or Degrading Treatment or Punishment,* បណ្ណាល័យសោតទស្សន៍ផ្នែកច្បាប់អន្តរជាតិរបស់អង្គការសហប្រជាជាតិ (អង្គការសហប្រជាជាតិ)ឆ្នាំ២០០៨ នៅទំព័រ១ ("សេចក្តីប្រកាសស្តីពីការធ្វើទារុណកម្ម គឺមានបំណងធ្វើជាចំណុចចាប់ផ្តើមសម្រាប់ការងារបន្តប្រឆាំងនឹងការធ្វើទារុណកម្ម... និយមន័យនៃពាក្យធ្វើទារុណកម្មនៅក្នុងសេចក្តីប្រកាសស្តីពីការធ្វើទារុណកម្មត្រូវបានគេចាត់ទុកថាមិនមានន័យច្បាស់លាស់គ្រប់គ្រាន់ ហើយត្រូវបានគេរិះគន់លើចំណុចផ្សេងៗ"។

[64] *សូមមើលរឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧- អ.វ.ត.ក/ក.ស.ច.ស សំណើសុំជាជម្រើសរបស់លោកអៀង សារី ស្តីពីការកំហិតនៃការអនុវត្តអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវនៅ អវតក ចុះថ្ងៃទី ០១ មិថុនា ២០១០ D ២៧៩/២, ERN: 00526277-00526292, កថាខណ្ឌ ៣៥ ។

ន័យនៃអំពើទារុណកម្មជាការរំលោភ លើគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់* (the principle of *nullum crimen sine lege*)[65]។ ប្រសិនបើការចោទពីអំពើទារុណកម្មអាចអនុវត្តបានជា "អំពើអមនុស្សធម៌ផ្សេងទៀត" នោះគោលការណ៍ណែនាំស្តីពីនិយមន័យដែលត្រូវយកមកអនុវត្តនោះ ត្រូវតែមានមាននៅក្នុងវិចារណកថា នៃអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩[66]។

## v. អាពាហ៍ពិពាហ៍ដោយបង្ខំ

២១. ដូចដែលសហាមេធាវីការពារក្តីបានធ្វើការពន្យល់កាលពីលើកមុន[67] ប៉ុន្តែ កសចស មិនទាន់បានពិចារណាសម្រេចនៅឡើយ[68] ការរៀបការដោយបង្ខំមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចរៀបរាប់នៅក្រោមច្បាប់ទំនៀមអន្តរជាតិពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ ឡើយ។ ហើយការរៀបការដោយបង្ខំក៏មិនបង្កើតបានជា "អំពើអមនុស្សធម៌ផ្សេងទៀត" ក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ នោះទេ[69]។ ការរៀបការដោយបង្ខំត្រូវបានទទួលស្គាល់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ("SCSL") តែប៉ុណ្ណោះ[70] ដែលមានយុត្តាធិការ

---

[65] ICCPR មាត្រា១៥(១)។ *សូមមើល*កថាខណ្ឌ៥ និង ៦*ដើងទំព័រខាងលើ*។

[66] *សូមមើល*អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា១៤៧ និងការធ្វើអត្ថាធិប្បាយ។ *សូមមើលផងដែររឿងក្តី អៀង សារី* សំណុំរឿងលេខ00២/១៩-0៩-២00៧- អ.វ.ត.ក/ក.ស.ច.ស សំណើសុំជាជម្រើសរបស់លោកអៀង សារី ស្តីពីការកំហិតនៃការអនុវត្តអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវនៅអវតក ចុះថ្ងៃទី ០១ មិថុនា ២០១០ D ២៧៩/២, ERN: 00526277-00526292, កថាខណ្ឌ ៣៣-៣៥ ។

[67] *សូមមើលរឿងក្តី អៀង សារី* សំណុំរឿងលេខ00២/១៩-0៩-២00៧- អ.វ.ត.ក/ក.ស.ច.ស សេចក្តីឆ្លើយតបរបស់លោក អៀង សារីទៅនឹងសំណើរបស់សហាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យមានកិច្ចស៊ើបសួរស្តីការរៀបការដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំ ថ្ងៃទី១១ ខែសីហា ឆ្នាំ២00៩ D188/3, ERN: 00362834-00362848 ("សេចក្តីឆ្លើយតបនឹងការរៀបការដោយបង្ខំ")។

[68] *សូមមើលរឿងក្តី អៀង សារី* សំណុំរឿងលេខ00២/១៩-0៩-២00៧- អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទិននឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២00៩ D268/2, ERN: 00417249- 00417254។

[69] *សូមមើល* សេចក្តីឆ្លើយតបនឹងការរៀបការដោយបង្ខំ កថាខណ្ឌ១០ និង១១។

[70] *សូមមើលរឿងក្តីរដ្ឋអាជ្ញាតទល់នឹង* Brima *et al.*, សំណុំរឿងលេខ SCSL-2004-16-A, សាលដីកា ("សាលដីកាអង្គជំនុំជម្រះសាលាឧទ្ធរណ៍ AFRC") ថ្ងៃទី២២ ខែកុម្ភះ ឆ្នាំ២00៨ កថាខណ្ឌ១៧៥-២០២។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *RUF* កថាខណ្ឌ១៦៤។ *សូមមើលផងដែរ* Neha Jain, *Forced Marriage as a Crime against Humanity: Problems of*

លើបទឧក្រិដ្ឋនានាដែលត្រូវបានប្រព្រឹត្តនៅក្នុង "ទឹកដីនៃប្រទេសសេរ៉ាឡេអូន ចាប់ពីថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៦ មក" [71]។ អញ្ចឹងហើយ ទើបការកំណត់ណាដែលធ្វើឡើងដោយតុលាការនោះថា ការរៀបការដោយបង្ខំគឺជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមច្បាប់ទំនៀមអន្តរជាតិ អនុវត្តតែចំពោះបទឧក្រិដ្ឋទាំងឡាយណា ដែលត្រូវបានប្រព្រឹត្តក្រោយកាលបរិច្ឆេទនេះប៉ុណ្ណោះ។ គួរឲ្យកត់សម្គាល់ផងដែរថា គ្មានអនុសញ្ញាអន្តរជាតិណាមួយដែលចាត់ទុកការរៀបការដោយបង្ខំថាខុសច្បាប់ ឬក៏ ពុំមានយុត្តិសាស្ត្រជាតិណាមួយដែលដាក់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការរៀបការដោយបង្ខំត្រូវបានអះអាងឬពឹងផ្អែកដោយ SCSL ឡើយ។ នេះមិនពិបាកទេ ដោយសារតែនៅក្នុងប្រទេសជាច្រើន ការរៀបការតាមការរៀបចំចាត់ចែងដោយអ្នកផ្សេង ឬ ដោយបង្ខំ ជាផ្នែកមួយនៃការទទួលយកក្នុងសង្គម បើទោះបីជាវាអាចជាគំនិតផ្ទុយទៅនឹងតម្លៃរបស់ពួកបស្ចិមប្រទេសក្តី[72]។ ដូច្នេះ ការរៀបការដោយបង្ខំពិតជាមិនត្រូវបានកំណត់ថាជាបទឧក្រិដ្ឋដោយច្បាប់ទំនៀមអន្តរជាតិក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ឡើយ។

**vi. ការបាត់ខ្លួនដោយបង្ខំ**

---

*Definition and Prosecution*, 6(5) J Int Criminal Justice 2008, 1013, 1014។ Michael Scharf & Suzanne Mattler, *Forced Marriage: Exploring the Viability of The Special Court for Sierra Leone's New Crimes Against Humanity,* អត្ថបទស្រាវជ្រាវនៅក្នុង Legal Studies អត្ថបទកំពុងស្រាវជ្រាវ ០៥-៣៥ ខែតុលា ឆ្នាំ២០០៥ នៅចំណុច២។ Amy Palmer, *An Evolutionary Analysis of Gender-Based War Crimes and the Continued Tolerance of "Forced Marriage"*, 7 NW.U.J.INT'L HUM.RTS.128, 137 (2009)។

[71] ច្បាប់លក្ខន្តិកៈ SCSL មាត្រា១។

[72] *ឧទាហរណ៍សូមមើល* អង្គភាពស្រាវជ្រាវ ELC *Are forced or arranged marriages a violation of human rights or valuable cultural practice which promote social cohesion?* *សូមមើលផងដែរ* M.M. Mehndiratta, B. Paul & P. Mehndiratta, *Arranged Marriage, Consanguinity and Epilepsy,* NEUROLOGY ASIA 12, 15-17 (2007)។ Binaya Kumar Bastia, *Socio-Cultural Aspects of Sexual Practices and Sexual Offences—An Indian Scenario,* 13 J. CLIN. FORENSIC MED. 208, 210 (2006)។ Michelle Vachon, *Book Examines 'Ritualcide' During KR Regime,* កាសែត Cambodia Daily ចុះផ្សាយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១០ ទំព័រទី១ ទី២ និងទី៤ "អាពាហ៍ពិពាហ៍ដែលបានរៀបចំ នៅតែជាទំនៀមទម្លាប់ប្រពៃណីនៃការរៀបអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជានៅឡើយ ហើយអ្នកដែលត្រូវបានសម្ភាសន៍. . .មិនបានប្រើពាក្យ 'បង្ខំ' ក្នុងការពិពណ៌នាអំពីការរៀបអាពាហ៍ពិពាហ៍របស់ខ្លួននៅក្នុងរបប[ខ្មែរក្រហម]ទេ"។

២២. ដូចដែលសហមេធាវីការពារក្តីបានធ្វើការពន្យល់កាលពីលើកមុន[73] ប៉ុន្តែ កសចស មិនទាន់បានពិចារណាសម្រេចនៅឡើយ[74] ការបាត់ខ្លួនដោយបង្ខំមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅដូចរៀបរាប់នៅក្រោមច្បាប់ទំនៀមអន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ឡើយ។ ហើយការបាត់ខ្លួនដោយបង្ខំក៏មិនបង្កើតបានជា "អំពើអមនុស្សធម៌ផ្សេងទៀត" ក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ នោះទេ[75]។ ពុំមានលិខិតុបករណ៍អន្តរជាតិណាមួយដែលចុះកាលបរិច្ឆេទមុនពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ រៀបរាប់ពីការបាត់ខ្លួនដោយបង្ខំថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះឡើយ[76]។ ទើបតែនៅឆ្នាំ ១៩៩២ ប៉ុណ្ណោះ ដែលមហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តសេចក្តីប្រកាសអំពីកិច្ចការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ[77]។ នៅមានទៀត សេចក្តីថ្លែងការណ៍នេះមិនមានលក្ខណៈចាប់បង្ខំទេ។ លិខិតុបករណ៍ដែលអាចចាប់ភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់លើកដំបូងនៅក្នុងវិស័យនេះ គឺអន្តរអនុសញ្ញាអាមេរិកស្តីពីការបាត់ខ្លួន ដោយបង្ខំត្រូវបានអនុម័តដោយមហាសន្និបាតរបស់អង្គការរបស់រដ្ឋអាមេរិកនៅឆ្នាំ១៩៩៤[78]។ លក្ខន្តិកៈរបស់តុលាការ ICTY មិនបានរៀបរាប់អំពីការបាត់ខ្លួនដោយបង្ខំថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ ហើយតុលាការ ICTY មិនដែលធ្វើការចោទប្រកាន់លើបទឧក្រិដ្ឋនេះឡើយ[79]។ ខណៈដែល ការបាត់ខ្លួនដោយបង្ខំ

---

[73] *សូមមើល* ចម្លើយតបទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ។

[74] ក.ស.ច.ស បានថ្លែងថាខ្លួន "នឹងមិនធ្វើការវិនិច្ឆ័យជាមុននូវដីកាដំណោះស្រាយដោយផ្តល់នូវការបកស្រាយច្បាប់ ទៅលើថាតើអង្គហេតុនឹងត្រូវកំណត់លក្ខណៈតាមច្បាប់យ៉ាងដូចម្តេច។" ដីកាទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ កថាខណ្ឌ៨។

[75] *សូមមើល* ការពិភាក្សានៅក្នុងចម្លើយតបទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ កថាខណ្ឌ២១-២៧ សម្រាប់ការពន្យល់ថាហេតុអ្វីប្រភពដែលមានកាលបរិច្ឆេទក្រោយសម័យកាលនោះ មិនអាចចាត់ទុកថាជាភស្តុតាងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

[76] *ដូចយោងខាងលើ*។

[77] G.A. Res. 47/133, U.N. G.A.O.R 47th Sess., របៀបវារៈ ៩៧(ខ) U.N. Doc A/RES/47/133 (1993)។ ទោះបីជាការពិតថាសេចក្តីថ្លែងការណ៍របស់មហាសន្និបាតអង្គការសហប្រជាជាតិ ត្រូវបានអនុម័តនៅខែធ្នូ ឆ្នាំ១៩៩២ក៏ដោយ ក៏មានរដ្ឋតិចតួចណាស់សូម្បីតែមកទល់បច្ចុប្បន្ននេះក្តី ដែលបានចាត់វិធានការណ៍ជាក់លាក់ក្នុងការអនុវត្តតាមមាត្រដ្ឋានរបស់សេចក្តីថ្លែងការណ៍នេះ។

[78] អនុសញ្ញានេះត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋជាសមាជិក OAS ចំនួន១៤ ក្នុងចំណោមរដ្ឋ៣៤ ដែលជាចំនួនស្ទើរតែមិនមែនជាភស្តុតាងនៃការអនុវត្តស៊ីសង្វាក់គ្នារបស់រដ្ឋដែលតម្រូវឲ្យមានដើម្បីការបង្កើតច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ តារាងរាយឈ្មោះរដ្ឋដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញានេះមាននៅលើគេហទំព័រ http://www.oas.org/juridico/english/sigs/a-60.html។

[79] ឯកសារពិគ្រោះតែមួយគត់ទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ គឺ *មិនមែនជាខ្លឹមសារសំខាន់ (obiter dictum)* មានចែងនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *Kupreškić* កថាខណ្ឌ៥៦៦ ដែលថ្លែងថាការបាត់ខ្លួនដោយបង្ខំ អាចត្រូវគេចាត់

សព្វថ្ងៃនេះ អាចត្រូវបានទទួលស្គាល់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងច្បាប់ទំនៀមអន្តរជាតិ បន្ទាប់ពីមានការផ្តល់សច្ចាប័នលើលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនៅឆ្នាំ១៩៩៨ក្តី[80] ក៏ការបាត់ខ្លួនដោយបង្ខំមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្រោមច្បាប់ទំនៀមអន្តរជាតិក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ឡើយ។

### vii. ការជម្លៀសដោយបង្ខំ

២៣. *ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានរៀបរាប់* ការជម្លៀសដោយបង្ខំមិនត្រូវបានរាប់ចូលនៅក្នុង ក) ធម្មនុញ្ញតុលាការយោធាអន្តរជាតិ (ខ) ធម្មនុញ្ញឆ្នាំ ១៩៤៦ របស់តុលាការយោធាអន្តរជាតិសម្រាប់ជ្រោយបូព៌ា (គ) ឬ គោលការណ៍ Nuremberg (ឃ) សេចក្តីព្រាងក្រម ឆ្នាំ ១៩៥៤ ស្តីពីបទល្មើសនានាប្រឆាំងនឹងសន្តិភាព និង សន្តិសុខរបស់មនុស្សជាតិឡើយ[81]។ ការមិនចែងពីការជម្លៀសដោយបង្ខំ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងលិខិតុបករណ៍ទាំងអស់នេះ បង្ហាញថា ការជម្លៀសដោយបង្ខំមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានចែងនៅក្នុងច្បាប់ទំនៀមអន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ នោះទេ។ ការជម្លៀសដោយបង្ខំ មិនមែនជាអនុប្រភេទនៃ "ការនិរទេស" នោះទេ។ "ការនិរទេស" តម្រូវឱ្យមានការឆ្លងកាត់ព្រំដែនរបស់រដ្ឋ *បើតាមច្បាប់* (*de jure*) ឬ នៅក្នុងកាលៈទេសៈខ្លះ *បើតាមហេតុ (de facto)* តម្រូវថាបានឆ្លងកាត់ព្រំដែន [82]។

---

ទុកថាជា "អំពើអមនុស្សធម៌ផ្សេងទៀត" ដោយផ្អែកលើសេចក្តីថ្លែងការណ៍ប្រកាសរបស់មហាសន្និបាតអង្គការសហប្រជាជាតិឆ្នាំ១៩៩២ និងអនុសញ្ញាអន្តរអាមេរិកកាំងឆ្នាំ១៩៩៤។

[80] លក្ខន្តិកៈតុលាការ ICC មាត្រា៧(១)(ឈ)។

[81] សូមកត់សំគាល់ថា ការជម្លៀសប្រជាជនពីផ្ទះសម្បែងដែលផ្ទះទាំងនោះបន្ទាប់មកត្រូវបានគេដុតបំផ្លាញ <u>អាច</u>ត្រូវគេបកស្រាយថាជា "អំពើអមនុស្សធម៌" នៅក្នុងសាលក្រមតុលាការយោធាអន្តរជាតិ (សាលក្រមតុលាការយោធាអន្តរជាតិ មាននៅលើគេហទំព័រ http://avalon.law.yale.edu/imt/judwarcr.asp)។ ប៉ុន្តែ "ទស្សនៈរបស់តុលាការចំពោះបញ្ហានៃការបកស្រាយនេះ គឺមិនដែលចែងឱ្យមានលក្ខណៈជាប្រព័ន្ធនៅក្នុង*សាលក្រម*នេះទេ ហើយត្រូវប្រមូលពីសាលក្រមផ្សេងៗដែលបានប្រកាសចំពោះជនជាប់ចោទម្នាក់ៗ។ ទាក់ទងនឹង["អំពើអមនុស្សធម៌"]. . . គឺមិនមានលក្ខណៈច្បាស់លាស់ពិតប្រាកដទេ ថាតើធ្លាប់មានការព្យាយាមបកស្រាយណាមួយដែរឬទេនោះ" (Sydney L. Goldenberg, *Crimes Against Humanity—1945-1970*, 10 W. Ontario L. Rev.1, 42 n.132a (1971))។

[82] *សូមមើល*សាលដីកាអង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Stakić* កថាខណ្ឌ២៧៨ និង ២៨៩ ។ *សូមមើលផងដែរ*សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *Brđanin* កថាខណ្ឌ៥៤២។ *សូមមើលផងដែរ* សាលក្រមអង្គជំនុំជម្រះសាលាដំបូង

ដោយសារតែការជម្លៀសដោយបង្ខំមិនតម្រូវឲ្យមានធាតុផ្សំនេះទេ នោះការជម្លៀសដោយបង្ខំត្រូវតែញែកចេញពីការនិរទេស។ ដូច្នេះ ដោយមិនធ្វើឲ្យប៉ះពាល់ដល់គោលជំហររបស់សហមេធាវីការពារក្ដី ដែលថា "អំពើអមនុស្សធម៌ផ្សេងទៀត" ជាប្រភេទមួយមិនអាចយកមកអនុវត្តបាន[83] នោះការចោទពីអំពើអំពើជម្លៀសដោយបង្ខំណាក៏អាចរំលោភលើមាត្រា ៥ នៃច្បាប់ស្ដីពីការបង្កើត អវតក ប្រសិនថា (ក) "អំពើអមនុស្សធម៌ផ្សេងទៀត"នោះ ជាប្រភេទអាចយកមកអនុវត្តបាន និង (ខ) ការជម្លៀសដោយបង្ខំផ្សំជា "អំពើអមនុស្សធម៌ផ្សេងទៀត" ក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ [84]។

**ឆ. "ការធ្វើទុក្ខបុកម្នេញ" ត្រូវកម្រិតព្រំដែនត្រឹមតែអំពើទាំងឡាយណាដែលមានទំនាក់ទំនងជាមួយនឹងបទឧក្រិដ្ឋផ្សេងទៀត ដែលមិតនៅក្នុងយុត្តាធិការរបស់ អវតក ហើយដែលមានស្ថានធម្ងន់ ប្រហាក់ប្រហែលនឹងអំពើទាំងឡាយដែលមានចែងនៅក្នុងមាត្រា ៥ នៃច្បាប់ស្ដីពីការបង្កើត អវតក**

---

ក្នុងរឿងក្ដី Blagojevic និង Jokic កថាខណ្ឌ ៥៩៧ ដល់ ៦០១ និង ៦៣៩ សម្រាប់ការពិភាក្សាទៅលើករណីលើកលែងចំពោះការហាមឃាត់សព្វថ្ងៃទៅលើការបាត់ខ្លួនដោយបង្ខំ នៅពេលដែលមិនអនុវត្តនូវសំអាងហេតុមួយក្នុងចំណោមសំអាងហេតុនានាដែលត្រូវបានគេទទួលស្គាល់ក្រោមច្បាប់អន្តរជាតិ។

[83] *សូមមើលកថាខណ្ឌ*១៣ ជើងទំព័រខាងលើ។

[84] ទាក់ទងនឹងរឿងនេះ *សូមមើល* THE UN INTERNATIONAL CRIMINAL TRIBUNALS នៅទំព័រ២២៤៖ "អង្គជំនុំជម្រះសាលារឿងក្ដី [*Stakić*] បានបង្ហាញថាខ្លឹមសារនៃការជម្លៀសដោយបង្ខំ ដែលចំណុចនេះអ្នកធ្វើសេចក្ដីព្រាងច្បាប់លក្ខន្តិកៈតុលាការ ICTY មិនដឹងនោះទេ ពីព្រោះថាពួកគេបានបញ្ចូលខ្លឹមសារនេះក្នុងមាត្រា៤ ថាជាអំពើមួយក្នុងចំណោមអំពើប្រល័យពូជសាសន៍មួយដែលអាចផ្ដន្ទាទោសបាន (ការជម្លៀសកុមារដោយបង្ខំពីក្រុមមួយទៅក្រុមមួយទៀត)។ ដូច្នេះ 'បញ្ហាដែលថា ការជម្លៀសដោយបង្ខំ មិនមាននិយាយច្បាស់ក្នុងមាត្រា៥ (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) ផ្ដល់ការគាំទ្របន្ថែមសម្រាប់ការមិនចាត់ទុកវាជាផ្នែកនៃ"អំពើអមនុស្សធម៌ផ្សេងទៀត" ដែលខុសពីការនិរទេស...' ការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្ដី *Stakić* គឺគ្រាន់តែជាការបង្ហាញឲ្យឃើញអំពីការបារម្ភមួយក្នុងចំណោមចៅក្រមនៅតុលាការនោះ ចំពោះលក្ខណៈមិនច្បាស់លាស់នៃប្រភេទអំពើអមនុស្សធម៌ផ្សេងទៀត...[ដែលវាមានលក្ខណៈទូទៅពេក *សូមមើល*កថាខណ្ឌ១៣*ជើងទំព័រខាងលើ*]។" ស្រដៀងគ្នានេះដែរ នៅ អ.វ.ត.ក "ការជម្លៀសដោយបង្ខំ" ត្រូវបានទទួលស្គាល់ក្នុងមាត្រា៤[ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍]នៃច្បាប់ស្ដីពីការបង្កើត[អ.វ.ត.ក]។ ដោយមូលហេតុនេះហើយ ការប្រព្រឹត្តនេះមិនគួរត្រូវគេចោទប្រកាន់ជា"អំពើអមនុស្សធម៌ផ្សេងទៀត" ឡើយ។

២៤. យោងតាមលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ អំពើធ្វើទុក្ខបុកម្នេញត្រូវបានសំដៅទៅលើអំពើទាំងឡាយ ដែលមានការទាក់ទងជាមួយនឹងបទឧក្រិដ្ឋផ្សេងទៀត ដែលឋិតនៅក្នុងយុត្តាធិការរបស់តុលាការ។ ច្បាប់ស្តីពីការបង្កើត អវតក មិនមានលក្ខខណ្ឌតម្រូវនេះទេ ឬក៏ មិនបានច្រានវាចោលឡើយ។ កិច្ចព្រមព្រៀងលើកយោងទៅរកនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ហេតុដូច្នេះ អវតក គួរកម្រិតព្រំដែនលើអំពើទាំងឡាយនៃការធ្វើទុក្ខបុកម្នេញត្រឹមតែអំពើទាំងឡាយ ដែលមានទំនាក់ទំនងជាមួយនឹងបទល្មើសនានាដែលឋិតនៅក្នុងយុត្តាធិការរបស់ខ្លួន[85]។ នៅតុលាការ ICTY អំពើធ្វើទុក្ខបុកម្នេញគឺជា "មានទម្ងន់ស្មើគ្នាទៅនឹងឧក្រិដ្ឋកម្មផ្សេងៗដែលមានរាប់បញ្ចូលនៅក្នុងមាត្រា ៥ នៃលក្ខន្តិកៈ [ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ]"[86]។ កសចស គួរទទួលយកការណែនាំផងដែរពីយុត្តធិការរបស់តុលាការ ICTY ដោយការកម្រិតព្រំដែនលើអំពើធ្វើទុក្ខបុកម្នេញ ត្រឹមតែអំពើទាំងឡាយដែលមាន "ស្ថានទម្ងន់ដូចគ្នានឹងបទឧក្រិដ្ឋដទៃៗផ្សេងទៀត ដូចដែលមានរៀបរាប់។

## ៤. "ការធ្វើទុក្ខបុកម្នេញ" ត្រូវតែកម្រិតត្រឹមអំពើទាំងឡាយដែលត្រូវបានប្រព្រឹត្តឡើងដោយមានចេតនាជាក់លាក់ ក្នុងការរើសអើងដោយមូលហេតុ នយោបាយ ពូជសាសន៍ និង សាសនា

២៥. មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អវតក កំណត់យ៉ាងច្បាស់លាស់ថា អំពើនានានៃ "ការធ្វើទុក្ខបុកម្នេញ" ត្រូវតែជាការប្រព្រឹត្តិដោយមូលហេតុនយោបាយ ពូជសាសន៍ និង សាសនា។ មាត្រា ៥(ជ) នៃលក្ខន្តិកៈតុលាការ ICTY និងមាត្រា ៣(ជ) នៃលក្ខន្តិកៈតុលាការ ICTR កំណត់ "ការធ្វើទុក្ខបុកម្នេញ"ប្រហាក់ប្រហែលគ្នា ថាត្រូវតែបានប្រព្រឹត្តិដោយមូលហេតុទាំងអស់នេះ[87]។ វាច្បាស់

---

[85] លក្ខន្តិកៈតុលាការ ICC មាត្រា៧(១)(ជ)។ *សូមមើលផងដែរ*កថាខណ្ឌ៥ និង៦ *ជើងទំព័រខាងលើ*។

[86] សាលដីកាអង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Kordić and Čerkez* កថាខណ្ឌ១០២-១០៣។ *សូមមើលផងដែរ* សាលដីកាអង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Blaskić* កថាខណ្ឌ១៣៥ និង១៣៨-១៣៩។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *Kupreškić* កថាខណ្ឌ៦១៨-១៩។

[87] សាលដីកាអង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Kordić and Čerkez* កថាខណ្ឌ ៧១១។ សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Vasiljevic , សំណុំរឿងលេខ IT-98-32-A សាលដីកា ថ្ងៃទី ២៥ កុម្ភៈ ២០០៤ កថាខណ្ឌ ១១៣។ រឿងក្តីរដ្ឋ

ណាស់ ដែលថា មានតែមូលហេតុនយោបាយ ជាតិសាសន៍ និង សាសនាប៉ុណ្ណោះដែលត្រូវបានចែងនៅក្នុងច្បាប់ស្តីពីការបង្កើត អវតក ទើបអាចត្រូវកំណត់ជាអំពើធ្វើទុក្ខបុកម្នេញនៅ អវតក។

២៦. នៅឯតុលាការ ICTY ចេតនាជាក់លាក់ក្នុងការរើសអើងដោយមូលហេតុ នយោបាយ ជាតិសាសន៍ និង សាសនា ត្រូវតែមានការបង្ហាញភស្តុតាងទាក់ទងទៅនឹងអំពើជាមូលដ្ឋាន (ដែលផ្ទុយគ្នាទៅនឹងការវាយប្រហារជាទូទៅ) ព្រមជាមួយគ្នានឹងចេតនាក្នុងការប្រព្រឹត្តអំពើជាមូលដ្ឋានផងដែរ[88]។ ចេតនានេះអាចមិនត្រូវបានទាញការ "សន្និដ្ឋានផ្ទាល់ពីប្រភេទនៃការរើសអើងទូទៅនៃការវាយប្រហារ ដែលត្រូវបានចរិតលក្ខណៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" នោះទេ[89]។ នៅអវតក

---

អាជ្ញាតទល់នឹង *Krnojelac,* សំណុំរឿងលេខ IT-97-25-A សាលដីកា ថ្ងៃទី ១៧ កញ្ញា ២០០៣ កថាខណ្ឌ ១៨៥។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី Brdanin កថាខណ្ឌ ៩៩៦។ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Simic et al., សំណុំរឿងលេខ IT-95-9-T សាលក្រមចុះថ្ងៃទី ១៧ តុលា ២០០៣(សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី Simic) កថាខណ្ឌ ៥១។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី Stakic កថាខណ្ឌ ៧៣៨. រឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Kordic & Cerkez,* សំណុំរឿងលេខ IT-95-14/2 សាលក្រម ថ្ងៃទី ២៦ កុម្ភៈ ២០០១ កថាខណ្ឌ ៣៥០, ៤៧០ ដល់ ៤៧១។ *ប៉ុន្តែសូមមើល* ចំពោះការទាក់ទងទៅនឹងហេតុផលជាតិពន្ធុនៅតុលាការ ICTR រឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Nahimana,* សំណុំរឿងលេខ ICTR-99-52-A សាលដីកា ថ្ងៃទី ២៨ វិច្ឆិកា ២០០៧ កថាខណ្ឌ ៩៨៦-៨៨ ។ សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Bagosora* សំណុំរឿងលេខ ICTR-98-41-T សាលក្រម ថ្ងៃទី ១៨ ធ្នូ ២០០៨ កថាខណ្ឌ ២២០៩។

[88] សាលដីកាអង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី Stakic កថាខណ្ឌ ៣២៨។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី Kordic & Cerkez កថាខណ្ឌ ២១៦-២១៧។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី Simic កថាខណ្ឌ ៥១។

[89] សាលដីកាអង្គជំនុំជម្រះ តុលាការកំពូលលើរឿងក្តី *Kordićc & CČerkez* កថាខណ្ឌ១១០។ ប៉ុន្តែ សូមកត់សំគាល់ថាអង្គជំនុំជម្រះ តុលាការកំពូលបានបន្ថែមថា៖ "អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ចេតនារើសអើងអាចត្រូវបានគេទាញការសន្និដ្ឋានពីបរិបទនេះ តាមការយល់ឃើញអំពីអង្គហេតុនៃរឿងក្តី ដរាបណាកាលៈទេសៈជុំវិញការប្រព្រឹត្តអំពើទាំងឡាយដែលត្រូវបានចោទប្រកាន់ចង្អុលភស្តុតាងអំពីអត្ថិភាពនៃចេតនានេះ"។ សូមធ្វើការអះអាងថា យុត្តិសាស្ត្រតុលាការ ICTY បានបន្ធូរបន្ថយនូវធាតុផ្សំ *អត្តនោម័ត* ដោយអនុញ្ញាតអោយមានការផ្តន្ទាទោសនៅក្នុងស្ថានភាពនានាដែលចេតនាពិសេសជាក់លាក់ មិនត្រូវបានគេរកឃើញ ដែលវាមានការប៉ះទង្គិចគ្រោះថ្នាក់ដល់គោលការណ៍នីត្យានុកូលភាព ដូចជា ជនជាប់ចោទម្នាក់ដែលត្រូវបានគេចោទប្រកាន់អំពីការធ្វើទុក្ខបុកម្នេញ អាចត្រូវបានផ្តន្ទាទោសដោយមិនចាំបាច់មានភស្តុតាងបង្ហាញអំពីអត្ថិភាពនៃចេតនាពិសេសចំពោះការធ្វើទុក្ខបុកម្នេញ ដោយសំអាងទៅលើ ការបញ្ជា ការធ្វើផែនការ ឬ ផ្តួចផ្តើមគំនិត ជួយ និងជំរុញ និងការទទួលខុសត្រូវព្រហ្មទណ្ឌតាមបែបសហឧក្រិដ្ឋកម្មរួម។ សូមមើល ផ្នែក J.7 នៃឧបសម្ព័ន្ធ សម្រាប់ការពិភាក្សាយ៉ាងពេញលេញទៅលើយុត្តិសាស្ត្រនេះ។ *សូមមើលផងដែរ* រឿងក្តី អៀងសារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស ពាក្យសុំរបស់លោក អៀង សារី ដែលជាជម្រើសមួយស្តីពីការដាក់កម្រិតលើការអនុវត្តទៅលើការទទួលខុសត្រូវរបស់ថ្នាក់លើនៅ អវតក ចុះថ្ងៃទី ១៥ កុម្ភៈ ២០១០ ឯកសារលេខ D345/3 ERN:0045746-0045757 កថាខណ្ឌ ២០-២១។ រឿងក្តី

ចេតនាជាក់លាក់ក្នុងការរើសអើងដោយមូលហេតុនយោបាយ ពូជសាសន៍ និង សាសនា ត្រូវតែពិចារណាចាត់ទុកជាធាតុផ្សំមួយនៃ *ចេតនាឧក្រិដ្ឋ* (*mens rea*) នៃ "ការធ្វើទុក្ខបុកម្នេញ"។

## III. សេចក្តីសន្និដ្ឋាន និងសំណើ

**អាស្រ័យហេតុនេះ** សម្រាប់មូលហេតុទាំងឡាយដូចបានថ្លែងបញ្ជាក់នៅក្នុងឯកសារនេះ មេធាវីការពារក្តីស្នើសុំដោយគោរពថា ប្រសិនបើសហចៅក្រមស៊ើបអង្កេតយល់ឃើញថា បើទោះជាសហមេធាវីការពារក្តីមានទឡ្ហីករណ៍ផ្ទុយជំទាស់ជាច្រើនក្តី ក៏ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអាចអនុវត្តបាននៅ អវតក នោះសហចៅក្រមស៊ើបអង្កេតគួរតែ ៖

ក. **កម្រិត** ការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចំពោះតែស្ថានភាពទាំងឡាយ ដែលថាជនត្រូវចោទ/ជនជាប់ចោទ បានដឹងអំពីការវាយប្រហារប៉ុណ្ណោះ បានហើយ។

ខ. **កម្រិត** ការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចំពោះតែអំពើទាំងឡាយ ដែលមានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធអន្តរជាតិប៉ុណ្ណោះ បានហើយ។

គ. **កម្រិត** ការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចំពោះតែអំពើទាំងឡាយ ដែលត្រូវបានប្រព្រឹត្តឡើងជាផ្នែកនៃការវាយប្រហារ អនុលោមតាម ឬ ជាការជួយសម្រេចគោលនយោបាយរបស់រដ្ឋ ឬ របស់អង្គការចាត់តាំងប៉ុណ្ណោះ បានហើយ។

ឃ. **កម្រិត** ការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចំពោះតែអំពើទាំងឡាយ ដែលត្រូវបានប្រព្រឹត្តឡើងជាផ្នែកនៃការវាយប្រហារដែលមានលក្ខណៈរើសអើងកើតឡើង ដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ជាតិសាសន៍ ឬ សាសនាប៉ុណ្ណោះ បានហើយ។

ង. **កម្រិត** ការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចំពោះតែអំពើជាមូលដ្ឋានទាំងឡាយ ដែលត្រូវបានកំណត់យ៉ាងច្បាស់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងច្បាប់ទំនៀម

---

អៀងសារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស សារណាបន្ថែមរបស់លោកអៀង សារី ជាជម្រើសមួយក្នុងពាក្យសុំរបស់គាត់ប្រឆាំងនឹងការអនុវត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅ អវតក ចុះថ្ងៃទី ២១ ធ្នូ ២០០៩ ឯកសារលេខ D240/2, ERN: 00421720-00421743 កថាខណ្ឌ ២០-២៦។

អន្តរជាតិ ក្នុងអំឡុងពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ប៉ុណ្ណោះ បានហើយ។

ច. **ប្រកាសថា** "អំពើអមនុស្សធម៌ផ្សេងទៀត" មិនអាចអនុវត្តបានជាប្រភេទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អវតក បានទេ ឬ កម្រិត "អំពើអមនុស្សធម៌ផ្សេងទៀត" តែត្រឹមអំពើទាំងឡាយ ដែលត្រូវបានកំណត់ឃើញបានយ៉ាងច្បាស់លាស់អញ្ចឹងឯងនៅអំឡុងពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ដំបូងយោងទៅនិយាមច្បាប់ព្រហ្មទណ្ឌ រួចហើយយោងទៅវករវិធាន *ដូចៗគ្នាហ្នឹងដែលមិនបានរៀបរាប់* (*ejusdem generis*)។

ឆ. **កម្រិត** "ការធ្វើទុក្ខបុកម្នេញ" ចំពោះតែអំពើទាំងឡាយ ដែលមានការទាក់ទងជាមួយនឹងឧក្រិដ្ឋកម្មនានា នៅក្នុងយុត្តាធិការរបស់ អវតក ដែលមានស្ថានទម្ងន់ប្រហាក់ប្រហែលទៅនឹងអំពើទាំងឡាយ ដែលមានចែងនៅក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អវតក និង ដែលត្រូវបានប្រព្រឹត្តឡើងដោយមានចេតនាជាក់លាក់ក្នុងការរើសអើង ដោយសារមូលហេតុនយោបាយ ជាតិសាសន៍ និង សាសនាប៉ុណ្ណោះ បានហើយ។

សូមចៅក្រមអង្គបុរេជំនុំជម្រះទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០១០

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA ព្រះរាជាណាចក្រកម្ពុជា

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីរបស់លោក **អៀង សារី**